# នីតិរដ្ឋដើម្បី សិទ្ធិមនុស្សក្នុង តំបន់អាស៊ានៈ ការសិក្សាជាមូលដ្ឋាន

លោក ម៉ាដេច ម៉ូហាន[i]

## I. ដំណើរការរៀបចំឯកសារសិក្សាស្រាវជ្រាវអំពីនីតិរដ្ឋ ដោយមជ្ឈមណ្ឌលធនធានសិទ្ធិមនុស្ស (HRRC)

### ក. សេចក្តីផ្តើម និងវិធីសាស្រ្តស្រាវជ្រាវ

១. "នីតិរដ្ឋ" គឺមានតម្លៃជានិម្មិតរូប។នៅក្នុងការអនុវត្តន៍ជាក់ស្តែង នីតិរដ្ឋមានឥទ្ធិពលត្រឹមកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ឯកសារសិក្សាស្រាវជ្រាវនេះ គឺជាមូលដ្ឋានមួយផ្តល់ជាជំនួយដល់ប្រទេសជាសមាជិកអាស៊ានក្នុងការយល់ដឹង ការពិចារណា និងការអនុវត្តន៍នីតិរដ្ឋនៅក្នុងគោលការណ៍អភិបាលកិច្ចល្អ ជាពិសេសពង្រឹងការគោរពសិទ្ធិមនុស្ស។

២. ការសិក្សាស្រាវជ្រាវនេះ គឺជាឯកសារដំបូងដែលពឹងផ្អែកតាមការស្រាវជ្រាវនៃប្រទេសនីមួយៗនៅក្នុងតំបន់ដោយក្រុមអ្នកសិក្សាស្រាវជ្រាវ និងក្រុមអ្នកសម្របសម្រួលដ៏មានជំនាញ។ នៅដំណាក់កាលដំបូងនៃការសិក្សាស្រាវជ្រាវ យើងធ្វើការវិភាគទៅលើព័ត៌មានបានមកពីប្រភពទីពីរ ដូចជា ទិន្នន័យរដ្ឋបាលសាលក្រមរបស់តុលាការ បទប្បញ្ញត្តិច្បាប់ សេចក្តីថ្លែងការណ៍នានារបស់រដ្ឋាភិបាល និងរបាយការណ៍របស់តតីយជន។ ចំពោះការសិក្សាស្រាវជ្រាវលម្អិត និងស៊ីជម្រៅ អាចនឹងប្រព្រឹត្តទៅនាពេលបន្តបន្ទាប់។

៣. ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់យន្តការពីរប្រភេទចំពោះការវិភាគ និងការយកសេចក្តីសន្និដ្ឋានរួម។ យន្តការទី១ គឺផ្តោតទៅលើការបកស្រាយទាំងឡាយរបស់ប្រទេសជាសមាជិកអាស៊ាន អំពីជោគជ័យក្នុងការអនុវត្តន៍គោលការណ៍នីតិរដ្ឋ ដោយពិនិត្យមើលលើការកំណត់ និងការអនុវត្តន៍ គួយ៉ាង តើកាលៈទេសៈណាដែលគោលគំនិតនេះត្រូវបានលើកឡើង? តើគោលការណ៍នីតិរដ្ឋត្រូវបានបកស្រាយដោយរបៀបណា? និង តើគោលការណ៍នេះត្រូវបានយកទៅអនុវត្តជាក់ស្តែងដែរឬទេ? នៅក្នុងរបាយការណ៍ប្រចាំប្រទេសនីមួយៗបានពិចារណា ថាតើរដ្ឋនោះជាភាគីនៃលិខិតូបករណ៍សិទ្ធិមនុស្សសំខាន់ៗហើយឬនៅ? ប្រសិនបើដូច្នោះ ថាតើកាតព្វកិច្ចនៃសន្ធិសញ្ញានោះត្រូវបានយកមកអនុវត្ត ឬដាក់បញ្ចូលនៅក្នុងច្បាប់ក្នុងស្រុក និងតុលាការយកទៅអនុវត្តដោយរបៀបណា?

៤. យន្តការផ្សេងទៀតដែលប្រើប្រាស់ក្នុងការវិភាគ គឺផ្អែកលើសូចនាករទូទៅ ដែលបានកំណត់ធាតុផ្សំចាំបាច់ និងខ្លឹមសារសំខាន់នៃគោលការណ៍នីតិរដ្ឋ ដូចជា ថាតើមន្ត្រីរដ្ឋាភិបាលបានទទួលខុសត្រូវចំពោះមុខច្បាប់ដែរឬទេ? ថាតើស្ថាប័ននីតិប្បញ្ញត្តិបានការពារសិទ្ធិជាមូលដ្ឋានស្របច្បាប់ និងអនុញ្ញាតឲ្យប្រជាពលរដ្ឋមានសិទ្ធិទទួលបានដំណើរការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដែរឬទេ? ធាតុផ្សំចាំបាច់ គឺតម្រូវឲ្យមានច្បាប់ដែលស្ថិតនៅក្នុងដែនវិសាលភាពមានទស្សនៈវិស័យច្បាស់លាស់ក្នុងការអនុវត្តន៍ និងមានមូលដ្ឋានច្បាស់លាស់ចំពោះការបង្កើត។"

៥. អត្ថបទច្បាប់ គឺមានតម្លៃជាងអក្សរចារិក ដោយសារតែកត្តានេះ ទើបធ្វើឲ្យក្រុមអ្នកស្រាវជ្រាវបានខិតខំស្វែងរកឯកសារជាក់លាក់ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលសំខាន់ៗនៃច្បាប់ដែលកំពុងអនុវត្ត ដូចជា ការពន្លាតដែនសូចនាករ ដែលបានអនុវត្តដោយស្ថាប័នយុត្តិធម៌ និង ថាតើស្ថាប័នតុលាការត្រូវបានផ្តល់នូវគុណតម្លៃ និងបានចាត់វិធានការសមស្របការពារសិទ្ធិរបស់រូបវន្តហើយឬនៅ?

៦. សំខាន់ជាងនេះ ឯកសារសិក្សាស្រាវជ្រាវនេះ មានគោលបំណងបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការយល់ដឹង អំពីនីតិរដ្ឋក្នុងបរិបទសិទ្ធិមនុស្សនៅអាស៊ាន ដែលពុំមែនជាឯកសារស្រាវជ្រាវលម្អិត អំពីទស្សនៈនៅក្នុងតំបន់ ឬក៏ជាសេចក្តីសង្ខេបដែលបង្ហាញពីលំដាប់ថ្នាក់នៃស្ថានភាពចំពោះការអនុវត្តន៍នីតិរដ្ឋរបស់រដ្ឋជាសមាជិកអាស៊ាននោះទេ។ ផ្ទុយទៅវិញ ឯកសារស្រាវជ្រាវនេះ គឺជាគម្រោងផ្តួចផ្តើមមួយ ៖ ដែលអាចប្រើជាឯកសារយោងសម្រាប់ការស្រាវជ្រាវលម្អិតនាពេលអនាគតពាក់ព័ន្ធនឹងកម្មវិធីនីតិរដ្ឋ និងភ្នាក់ងារសិទ្ធិមនុស្សនៅក្នុងតំបន់ ក៏ដូចជា ភាគីពាក់ព័ន្ធនានា ដែលមានបំណងលើកកម្ពស់នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សផ្អែកទៅតាមធម្មនុញ្ញអាស៊ាន។

៧. ឯកសារស្រាវជ្រាវនេះ បានផ្តល់ពីទិដ្ឋភាពទូទៅនៃយុទ្ធសាស្ត្រក្នុងការវាស់ស្ទង់ពីការអនុវត្តន៍គោលការណ៍នីតិរដ្ឋ - ការអត្ថាធិប្បាយពីគោលការណ៍ស្នូលរបស់នីតិរដ្ឋ និងសូចនាករ - របកគំហើញជាបឋមពីរដ្ឋជាសមាជិកអាស៊ាន - ការពិភាក្សាអំពីបញ្ហាប្រឈម និងមេរៀនដកពិសោធន៍អំពីដំណើរការនេះ - ព្រមទាំងបានផ្តល់ជាអនុសាសន៍ដោយឲ្យមានការស្រាវជ្រាវបន្ថែម ការវិភាគបន្ថែម និងការកសាងពង្រឹងសមត្ថភាពជាបន្តបន្ទាប់។

## ខ. ទិដ្ឋភាពរួមនៃនីតិរដ្ឋនៅអាស៊ាន

១. មុននឹងបង្ហាញពីខ្លឹមសារសង្ខេបនៃរបកគំហើញនេះ យើងសូមធ្វើការបង្ហាញពីការយល់ឃើញជារួមនៃពាក្យនីតិរដ្ឋ គឺថា "ជាការយល់ដឹងពីធាតុផ្សំមូលដ្ឋាន"។ តាមរយៈការជជែកពិភាក្សាជាច្រើនពីនិយមន័យនៃពាក្យនេះ បានបង្ហាញថា គួរមានការលើកកម្ពស់ការអនុវត្តន៍និងការពង្រឹងនីតិរដ្ឋ។[iii] ជាបន្ទាប់ យើងនឹងពិចារណាពីការចាប់ផ្តើមចេញដំណើររបស់អាស៊ានចំពោះការយល់ឃើញជាទូទៅ ជាមួយនឹងការអនុម័តធម្មនុញ្ញអាស៊ាន និងការវិវត្តន៍ថ្មីៗរបស់ខ្លួន។

២. រដ្ឋ និងអ្នកបង្កើតគោលនយោបាយច្បាប់ គឺមានគោលបំណងចង់បង្ហាញតែហេតុវិជ្ជមាន អំពីការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។ ចំពោះកំណើតនៃពាក្យនីតិរដ្ឋ គឺមានការគាំទ្រ "តិចតួចណាស់" ដែលដំបូងផ្តោតតែទៅលើទិដ្ឋភាពចាំបាច់ ឬទិដ្ឋភាពច្បាប់ប៉ុណ្ណោះ ដោយមិនគិតពីសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទេ។[iv] យោងតាម Joseph Raz៖

*"ពាក្យ 'នីតិរដ្ឋ' គឺមានន័យថា 'ជាការគ្រប់គ្រងដោយច្បាប់'"*[v]

៣. ទោះបីជាយ៉ាងណា ទស្សនៈពិតប្រាកដនៃពាក្យនីតិរដ្ឋ គឺអាចបញ្ជាក់ច្បាស់នៅពេលអនុវត្ត។ លោក Gordon Barron បានអះអាងដោយជឿជាក់ថា ដើម្បី "បង្ហាញពីការយកចិត្តទុកដាក់របស់ខ្លួនក្នុងការលើកកម្ពស់ការយល់ដឹងអំពីនីតិរដ្ឋ ជាផ្លូវការណ៍ និងតាមបច្ចេកទេស"[vi] ធនាគារពិភពលោកបានទប់ស្កាត់នូវលទ្ធភាពក្នុងការជំរុញឲ្យមានកំណែទម្រង់នីតិរដ្ឋប្រកបដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ៖

*"តម្រូវការឲ្យមានការយកចិត្តទុកដាក់ទៅលើស្ថាប័នច្បាប់សេដ្ឋកិច្ច គឺពិតជាមានភាពចាំបាច់ ដើម្បីដាក់កំហិតឲ្យធនាគារពិភពលោកផ្តោតការយកចិត្តទុកដាក់ទៅលើប្រព័ន្ធ*

*ច្បាប់ និងនីតិរដ្ឋ និងកម្រិតជាក់ច្បាស់ពីលទ្ធភាពរបស់ធនាគារ ដើម្បីជួយ "កសាង" នីតិរដ្ឋ"។*[vii]

៤. នៅក្នុងដំណាក់កាលដំបូង នីតិរដ្ឋ គឺពុំបានប្រើប្រាស់ឲ្យស្របន័យដើមទេ ឧទាហរណ៍ អំណាចគ្រប់គ្រងរដ្ឋត្រូវបានកំណត់ដោយច្បាប់ជាជាងការប្រើប្រាស់អំណាចបុគ្គល។[viii] ផ្ទុយទៅវិញ នីតិរដ្ឋត្រូវបានវិវត្តន៍ប្រសើរជាងមុន ការសម្រេចនានាពុំចាំបាច់មានការចូលរួមពីអំណាចនីតិប្រតិបត្តិ។ នៅឆ្នាំ១៩៩៥ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃប្រទេសសឹង្ហបុរី បានថ្លែងថា ទស្សនៈអំពីនីតិរដ្ឋ គឺ "មិនខុសប្លែកពីការយល់ឃើញ និងការទទួលយករបស់រដ្ឋនាពេលបច្ចុប្បន្ននេះទេ" ម្យ៉ាងទៀត ត្រូវតែស្របនឹង "លក្ខខណ្ឌចាំបាច់" ដែលអនុញ្ញាតឲ្យរដ្ឋាភិបាល "បង្កើត និងដំណើរការកាន់តែជោគជ័យ"។[ix] នៅប្រទេសម៉ាឡេស៊ី ទោះបីជាមានការទទួលស្គាល់ជាផ្លូវការណ៍ (នៅក្នុងក្រមស្តីពីសិទ្ធិស្របច្បាប់ និងសិទ្ធិនយោបាយ) ក៏គោលការណ៍ថ្នាក់ជាតិនៃប្រទេសនេះ (Rukunegara) នីតិរដ្ឋពុំត្រូវបានបកស្រាយក្នុង "ន័យជាក់លាក់ដែលមានការត្រួតពិនិត្យ និងមានតុល្យភាពចំពោះការយល់ដឹងជាទូទៅនៅក្នុងប្រព័ន្ធច្បាប់ប្រជាធិបតេយ្យ" ប៉ុន្តែផ្ទុយទៅវិញ ត្រូវបានអះអាងថា "ពាក្យនេះមិនមានន័យលើសពីវិធាន និងបទបញ្ញា ដែលចេញដោយរដ្ឋាភិបាល ហើយត្រូវតែគោរពតាម"។[x]

៥. ជាងនេះទៀត ទស្សនៈដំបូងនៃនីតិរដ្ឋ គឺមានន័យថា ជាវិធានច្បាប់ដែលធ្វើឲ្យរាល់សកម្មភាពរបស់រដ្ឋជៀសផុតពីការរិះគន់។ នៅប្រទេសឥណ្ឌូនេស៊ី ពាក្យនីតិរដ្ឋ ឬ Negara Hukum ត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ (ដែលមានប្រភពមកពីអឺរ៉ុប)។ មុនពេលមានចលនាប្រជាធិបតេយ្យនៅទសវត្សន៍ទី៩០ ពាក្យនេះត្រូវបានសំដៅទៅលើកំណែទម្រង់ (Reformasi) គោលការណ៍នេះត្រូវបានបកស្រាយកាន់តែចង្អៀតដើម្បីធ្វើឲ្យមានភាពស្របច្បាប់ ឬការពារអំណាចរបស់នីតិប្រតិបត្តិ។[xi] ឧទាហរណ៍ បទបញ្ញាថ្មីរបស់រដ្ឋាភិបាល **ស៊ូហាតូ** នៅចុងទសវត្សរ៍ទី៦០ តែងតែអះអាងថា "វិធានច្បាប់" គឺជាច្បាប់បង្កើតឡើងដោយ និងសម្រាប់តែពួកអភិជន ហើយត្រូវបានដាក់ឲ្យអនុវត្តដោយគ្មានសមធម៌។[xii]

៦. ការទទួលស្គាល់នូវសារៈសំខាន់នៃនីតិរដ្ឋនៅក្នុងដំណើរការប្រកបដោយប្រសិទ្ធិភាព នៅក្នុងទស្សនៈដំបូង "a thin conception" បាននឹងកំពុងប្រឈមមុខចំពោះការមិនអនុវត្តច្បាប់ ឬការផ្ទុយច្បាប់ ដែលលោក Thom Ringer បានលើកឡើងថា "សមភាពចំពោះមុខច្បាប់ និងការប្រព្រឹត្តស្មើគ្នា បានធ្វើឲ្យនីតិរដ្ឋក្លាយជាឧត្តមគតិដ៏លេចធ្លោនាពេលនេះ"។[xiii] បន្ទាប់មក ការពន្លាតច្បាប់ គឺកើតចេញពីស្មារតីសីលធម៌ ដែលមិនបានធានាថា គោលដៅនៃការយល់ឃើញដំបូងរបស់ពាក្យនេះ ដូចជាប្រសិទ្ធភាពភាពត្រឹមត្រូវ ឬការប្រមើមើលទុកជាមុននៃច្បាប់នឹងនៅស្ថិតស្ថេរនោះទេ។ ឧទាហរណ៍ ប្រទេសកម្ពុជា ឡាវ និងវៀតណាម បានអនុម័តនូវទស្សនៈដំបូងនៃពាក្យនីតិរដ្ឋនៅទសវត្សរ៍ទី៩០ ប៉ុន្តែគណបក្សកាន់អំណាចក្នុងប្រទេសទាំងនេះ គឺហាក់មានឋានុក្រមខ្ពស់ជាងច្បាប់ ដូច្នេះការគ្រប់គ្រងរដ្ឋ គឺពុំមានប្រសិទ្ធភាពទេ។

៧. លោក Ronald Bruce St John បានបង្ហាញគំនិតជាពិសេសមួយថា ៖

*"ជាផលវិបាកក្នុងរយៈពេលពីទសវត្សរ៍ក្រោយឆ្នាំ១៩៧៥រដ្ឋាភិបាលកម្ពុជា ឡាវ និង វៀតណាម បានប្រឈមនឹងឧបសគ្គដ៏ធំ ក្នុងការធ្វើឲ្យនីតិរដ្ឋមានប្រសិទ្ធភាព ដោយសារតែភាពប្រទាំងប្រទិសរវាងការគោរពអំណាច ទំនៀមទម្លាប់ និងក្របខណ្ឌច្បាប់ ដែលអ្នកសេដ្ឋកិច្ច និងអ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនបានពិចារណាថា មានសារៈសំខាន់ចំពោះទីផ្សារសេដ្ឋកិច្ច"។*[xiv]

៨. បញ្ហាប្រឈមទៅនឹងការយល់ឃើញដំបូងនៃនីតិរដ្ឋ អ្នកស្រាវជ្រាវជាច្រើនបានលើកឡើងនូវ "ទស្សនៈស៊ីជម្រៅមួយ" ដែលជាការច្របាច់បញ្ចូលគ្នារវាងច្បាប់ទំនៀមទម្លាប់ចំពោះការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងបទប្បញ្ញត្តិនានា។[xv]

៩. នៅក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ប្រទេសថៃ និងហ្វីលីពីន មានប្រវត្តិយល់ឃើញដូចគ្នាទៅលើនិយមន័យនៃទស្សនៈស៊ីជម្រៅនៃនីតិរដ្ឋ ដោយរួមបញ្ចូលគោលគំនិតដូចជាសិទ្ធិមនុស្ស និង អភិបាលកិច្ចល្អ។ ប្រទេសថៃបានកំពុងធ្វើ "បច្ចុប្បន្នភាពច្បាប់ឲ្យស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចសង្គម និង ការការពារសិទ្ធិបុគ្គលឲ្យស្របទៅនឹងគោលការណ៍នីតិរដ្ឋ"។[xvi] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៧ របស់ប្រទេសហ្វីលីពីន បានថែងពីការការពារស្របច្បាប់ និងសេរីភាព ដែលកើតឡើងតាមរយៈបទពិសោធន៍នៃការអនុវត្តន៍ច្បាប់ សង្គ្រាមរបស់ប្រទេសនេះ។ ទោះបីជាយ៉ាងណា របាយការណ៍សិក្សាស្រាវជ្រាវរបស់យើងបានបង្ហាញថា ការធានានូវការគោរពសិទ្ធិមនុស្សតាមរយៈនីតិរដ្ឋ គឺពុំត្រូវបានយកទៅប្រើក្នុងការអនុវត្តន៍ជាក់ស្តែងឲ្យមាន ប្រសិទ្ធិភាពនោះទេ។

១០. ទស្សនៈស៊ីជម្រៅនៃនីតិរដ្ឋ ក៏នៅមានចំណុចអវិជ្ជមានក្នុងករណីដែលយកទៅអនុវត្តលើសពីទ្រឹស្តីដើម។ បើផ្អែកទៅលើទស្សនៈនេះ នីតិរដ្ឋ គឺមានគុណសម្បត្តិជាច្រើនចាប់តាំងពីសមភាពសង្គមប្រជាធិបតេយ្យរហូតដល់សមភាពយេនឌ័រ ពីប្រព័ន្ធបោះឆ្នោតដ៏រឹងមាំរហូតដល់សុខុមាលភាពសង្គម។[xvii]

១១. ទស្សនៈអរូបីនេះ អាចបណ្តាលឲ្យមានភាពមិនច្បាស់លាស់ មិនដូចដែលបានកំណត់ពិតប្រាកដនៅក្នុងនីតិរដ្ឋ ថាតើនីតិរដ្ឋមានន័យគ្រប់យ៉ាង ដូចដែលបានលើកឡើងដែរឬទេ?[xviii] តាមការលើកឡើងរបស់លោក Brian Tamanaha ៖

*"នីតិរដ្ឋ គឺមិនល្អគ្រប់ករណីដូចដែលប្រជាពលរដ្ឋប្រាថ្នាចង់បានពីរដ្ឋាភិបាលនោះទេ។ ការជម្រុញឲ្យមានការលើកឡើងបែបនេះ គឺជាការបកស្រាយថា នីតិរដ្ឋគឺជានិម្មិតរូបនៃអំណាច ប៉ុន្តែកុំមានសុទិដ្ឋិនិយម"។*[xix]

១២. ជាងនេះទៀត បើសិននីតិរដ្ឋត្រូវបានទុកឲ្យមានន័យទូទៅ 'ជាយុត្តិធម៌សង្គម' 'ទស្សនៈស៊ីជម្រៅនៃនីតិរដ្ឋ' អាចនឹងត្រូវបានគេយកទៅបកស្រាយ ដើម្បីជាប្រយោជន៍របស់បុគ្គលដែលខ្លួនយល់ថាត្រឹមត្រូវ។

១៣. ក្នុងន័យនេះ ពាក្យនីតិរដ្ឋ អាចត្រូវអ្នកច្បាប់បរទេស និងម្ចាស់ជំនួយប្រើប្រាស់ជាអាវុធផ្សព្វផ្សាយពីទ្រឹស្តីជាតិពន្ធ និងគោលនយោបាយ ដោយមិនគិតថាតើទ្រឹស្តី ឬគោលនយោបាយនោះឆ្លើយតបនឹងតម្រូវការរបស់សហគមន៍នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ចាប់តាំងពីមានជំនួយពីអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩២-១៩៩៣ ប្រទេសកម្ពុជាបានទទួលជំនួយរាប់ពាន់លានដុល្លារ ដើម្បីកំណែទម្រង់ស្ថាប័នយុត្តិធម៌ ប៉ុន្តែជំនួយទាំងនោះមិនសុទ្ធតែទទួលបានលទ្ធផលជាវិជ្ជមាននោះទេ ដោយសារកង្វះការវាយតម្លៃជាក់ស្តែងទៅលើមូលដ្ឋានក្នុងស្រុក។[xx] ផ្ទុយទៅវិញ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលផ្តល់សេវាសម្របសម្រួលជម្លោះផ្ទៃក្នុងនៅថ្នាក់ភូមិ និងថ្នាក់ឃុំត្រូវបានប្រជាជនកម្ពុជាវាយតម្លៃថា "មានភាពងាយស្រួល ចំណាយថវិការតិច និងមានប្រសិទ្ធិភាពជាងយន្តការថ្នាក់ជាតិ"។[xxi]

១៤. ពាក្យនីតិរដ្ឋ ក៏ត្រូវបានប្រើប្រាស់ជារបាំងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងគោលបំណងចង់លុបបំបាត់ ឬមិនឲ្យតម្លៃទៅលើសិទ្ធិបុគ្គល និងដើម្បីឲ្យស្របច្បាប់ចំពោះការគ្រប់គ្រងតាមបែបកុម្មុយនីស្តរបស់ខ្លួន។ នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងបាងកកឆ្នាំ១៩៩៣ ក្រោមអធិបតីភាពនៃប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងសឹង្ហបុរី បានចង្អុលបង្ហាញថា "គុណតម្លៃ" របស់អាស៊ាន គឺមិនដូចគ្នាទៅនឹងទស្សនៈរបស់លោកខាងលិចទេ បើពិនិត្យទៅលើសិទ្ធិបុគ្គល។ លោក Vitit Muntarbhorn បានពន្យល់ថា ការអនុវត្តន៍នីតិរដ្ឋនៅអាស៊ានគឺត្រឹមតែទស្សនៈច្របូកច្របល់របស់ប្រទេសលោកខាងលិចប៉ុណ្ណោះ។

> "ទោះបីជា ពាក្យនីតិរដ្ឋមានវត្តមាននៅត្រឹមកម្រិតការគិតពិចារណារបស់បញ្ញាវ័ន្ត ក៏ពាក្យនេះហាក់ដូចជាមិនទាន់មានន័យច្បាស់លាស់ មានន័យថា នៅពេលពាក្យនេះត្រូវបានយកទៅប្រើប្រាស់ គឺតែងសន្មតថាមានយល់ដឹងពីន័យជាក់លាក់របស់វា ប៉ុន្តែជាក់ស្តែងអត្ថន័យនៃពាក្យនេះ ពុំត្រូវបានយល់ច្បាស់នោះទេ ឬបានពន្យល់ដោយស៊ីជម្រៅទៅដល់ប្រជាពលរដ្ឋ។ ពាក្យនីតិរដ្ឋក្នុងភាសាថៃ គឺ "Luck Nititham" ដែលត្រូវបានគេយល់ថា ជាវិធានផ្នែកច្បាប់ ដែលមានភាពយុត្តិធម៌ និងស្អាតស្អំ ប៉ុន្តែជាក់ស្តែងពាក្យនេះមិនងាយស្រួលក្នុងការកំណត់ន័យឲ្យច្បាស់លាស់នោះទេ។ ដូច្នេះ នៅតែមានភាពភ័ន្តច្រឡំថា នីតិរដ្ឋ គឺជាផ្នែកមួយដ៏សំខាន់របស់សង្គម ប៉ុន្តែតថភាពជាក់ស្តែងគេនៅតែមិនទាន់អាចយល់ដឹងស៊ីជម្រៅអំពីពាក្យនេះ។ ភាពមិនយល់ដឹងស៊ីជម្រៅនៃពាក្យនេះ គឺបណ្តាលមកពីគម្លាតរវាងការយល់ដឹងរបស់សមញ្ញជន និងទស្សនៈច្បាប់ដូចសុភាសិតថា 'ការគ្រប់គ្រងបែបរឿងនិទាន'។"[xxii]

១៥. ជាការពិត យើងមិនជំទាស់ថាមិនគួរឲ្យមានបទដ្ឋានអន្តរជាតិចំពោះទ្រឹស្តីនីតិរដ្ឋ ឬមិនគួរឲ្យរដ្ឋាភិបាលកំណត់កម្រិតនៃការយកទ្រឹស្តីនីតិរដ្ឋទៅប្រើប្រាស់ទៅតាមស្ថានភាពវប្បធម៌សង្គមនោះទេ។ ក្នុងន័យនេះ គឺថា ការដែលយកទ្រឹស្តីនីតិរដ្ឋទៅប្រើប្រាស់ ដើម្បីកេងចំណេញនយោបាយ គឺពិតជាមិនមានប្រយោជន៍ មិនថាអ្នកនយោបាយនោះអះអាងថា ដើម្បីពង្រឹងការអភិវឌ្ឍន៍នៅអាស៊ាន ឬនៅប្រទេសលោកខាងលិច។

១៦. ជាចុងបញ្ចប់ គឺថា នៅក្នុងទស្សនៈស៊ីជម្រៅចំពោះទ្រឹស្តីនីតិរដ្ឋ ពិតជាមានហានិភ័យក្នុងការដែលព្យាយាមដាក់បន្ទុកច្បាប់ឲ្យទទួលខុសត្រូវទៅលើសង្គម និងធ្វើឲ្យសង្គមមានយុត្តិធម៌។ ការដាក់បន្ទុក

បែបនេះ អាចជាការផ្តល់អំណាចយ៉ាងខ្លាំងដល់ចៅក្រមក្នុងការកំណត់ការចង់បានរបស់សង្គម ព្រោះថា ចៅក្រមពុំកើតចេញពីការបោះឆ្នោតជ្រើសតាំងឡើយ។ លោក Jeremy Waldron ដែលជាអ្នកស្រាវជ្រាវជាន់ខ្ពស់បារម្ភថា ទស្សនៈបែបនេះ អាចខ្វាស់ទៅនឹងលទ្ធផលប្រជាធិបតេយ្យ ហើយអាចប្រជែងទៅនឹងតួនាទីរបស់នីតិប្បញ្ញត្តិ។[xxiii]

១៧. ជាសរុប ទាំងទស្សនៈស៊ីជម្រៅ ឬទស្សនៈដំបូង នៃទ្រឹស្តីនីតិរដ្ឋ គឺមិនមានទ្រឹស្តីមួយណាប្រសើរជាងមួយណាទេ។ ទស្សនៈទាំងពីរមានចំណុចខ្លាំង និងចំណុចខ្សោយដូចគ្នា។ ចំពោះឯកសារស្រាវជ្រាវរបស់យើង ដែលពាក់ព័ន្ធនឹងព័ត៌មាន និងទស្សនៈបច្ចុប្បន្នភាពចំពោះនីតិរដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានស្នើឡើងថា រដ្ឋាភិបាលមិនគួររឹតត្បិតចំពោះនិយមន័យនៃពាក្យនីតិរដ្ឋ ដែលអាចក្លាយជា "សមរភូមិប្រយុទ្ធ" ចំពោះបញ្ហានយោបាយ និងសង្គម ហើយក៏មិនគួរមិនទទួលយកទស្សនៈណាមួយនៃនីតិរដ្ឋដែរ។[xxiv] ដើម្បីបង្កើនតម្លៃនៅអាស៊ាន ទ្រឹស្តីនីតិរដ្ឋមិនគួរមានន័យអរូបីពេក។ ទ្រឹស្តីនីតិរដ្ឋត្រូវតែមានក្របខណ្ឌឯកវាជ្យ មានបទដ្ឋានសម្រាប់វាយតម្លៃការអនុវត្តន៍ និងត្រូវបានវិភាគនៅក្នុងបរិបទជាក់ស្តែង ដែលនេះជាគោលបំណងរបស់ឯកសារស្រាវជ្រាវរបស់យើង។

<u>គ- នីតិរដ្ឋនៅអាស៊ាន ៖ ពីទស្សនៈចម្រូងចម្រាសឈានទៅរកក្របខណ្ឌទស្សនៈរួម</u>

១. ជាដំបូង ទ្រឹស្តីនីតិរដ្ឋ គឺមិនត្រូវបានយល់ជារួមនោះទេនៅក្នុងប្រទេសអាស៊ាន ប៉ុន្តែទស្សនៈនេះត្រូវបាន "ផ្លាស់ប្តូរ"[xxv]យ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០០៤ ឯកសារស្រាវជ្រាវដ៏សំខាន់មួយ ស្តីពីនីតិរដ្ឋនៅអាស៊ាន អ្នកនិពន្ធបានកំណត់ពីលក្ខណៈប្រទេសនៅអាស៊ានថាជាតំបន់ដែលទ្រឹស្តីនីតិរដ្ឋមាន "លក្ខណៈប្រកួតប្រជែង"។[xxvi]

២. លើកលែងតែប្រទេសកុំម្មុយនីស្តពីរ ប្រទេសវៀតណាម និងឡាវ អ្នកស្រាវជ្រាវបានចាត់ចំណាត់ថ្នាក់អាស៊ានជាពីរប្រភេទ ទី១-ប្រទេសផ្តាច់ការ ឬផ្តាច់ការបែបទន់ភ្លន់ ឬប្រជាធិបតេយ្យមានកម្រិត រួមមានប្រទេសភូមា ម៉ាឡេស៊ី សឹង្ហបុរី និងប្រ៊ុយណេ។ ទី២-ប្រទេសដែលគ្រប់គ្រងដោយរដ្ឋធម្មនុញ្ញ យុត្តិធម៌អន្តរកាល រួមមាន ប្រទេសកម្ពុជា ហ្វីលីពីន ថៃ និងឥណ្ឌូនេស៊ី។ ចំណាត់ថ្នាក់ទាំងពីរប្រភេទនេះ ត្រូវបានប្រៀបធៀប និងឆ្លុះបញ្ចាំងពីភាពផ្ទុយគ្នា ចំពោះលទ្ធិប្រជាធិបតេយ្យនៅក្នុងតំបន់ និងប្រទេសលោកខាងលិច។[xxvii]

៣. ផ្អែកទៅតាមទ្រឹស្តីនេះ លោក Randall Peerenboon បានធ្វើសេចក្តីសន្និដ្ឋានថា នៅពេលដែលប្រព័ន្ធច្បាប់ក្នុងតំបន់ជាទូទៅមិនស្របនឹងទស្សនៈដំបូង "ការកម្រិតភាពសកលនិយមមួយ" ត្រូវបានកំណត់ ប៉ុន្តែ "ទ្រឹស្តីនេះបានបាត់បង់ប្រជាប្រិយភាពនៅពេលប្រជែងជាមួយទស្សនៈស៊ីជម្រៅ"។[xxviii] លោកសាស្ត្រាចារ្យ Peerenboon បានបន្ថែមថា "ការពិភាក្សាអំពីនយោបាយ និងច្បាប់ជាច្រើននាពេលបច្ចុប្បន្ន បានបង្កើតឡើងដោយមិនបានយល់ដឹងពីសញ្ញាណឬសនៃពាក្យនីតិរដ្ឋ។ ទោះបីជាការពិភាក្សានោះមិនឃ្លាតចាកឆ្ងាយពីទស្សនៈស៊ីជម្រៅ ក៏ត្រូវឲ្យមានការបកស្រាយឲ្យទូលំទូលាយ"។[xxix]

៤. ការផ្លាស់ប្តូរនៃកាលវេលា តាមការសិក្សាស្រាវជ្រាវរបស់យើងបានបង្ហាញថា អាស៊ានបានធ្វើជាម្ចាស់នៃ "បដានីតិរដ្ឋ" ដែលការរៀបចំឲ្យមានក្របខណ្ឌអនុវត្តនីតិរដ្ឋជាក់ស្តែង។ ដូច្នេះ នីតិរដ្ឋត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយនៅក្នុងតំបន់ និងដោយមានការលើកកម្ពស់។

៥. ការអនុវត្តន៍នីតិរដ្ឋក្នុងប្រទេសជាសមាជិកអាស៊ាន គឺមានកម្រិតខុសៗគ្នា អាស្រ័យទៅតាមបរិបទ និងស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗ ទោះបីជា ភាពខុសគ្នានេះ មិនបានឆ្លុះបញ្ចាំងពីទស្សនៈនៃ 'ការប្រកួតប្រជែង' ក៏ភាពខុសគ្នានៃបទដ្ឋានត្រូវបានលេចឡើងនៅអាស៊ាន។

៦. ម្យ៉ាងទៀត តាមរយៈការសិក្សាស្រាវជ្រាវនេះ បានលើកឡើងថា ការវិវត្តន៍ថ្មីៗនៅក្នុងសកលលោក និងក្នុងតំបន់ បានលេចចេញកាន់តែច្បាស់ និងមុតមាំអំពីធាតុផ្សំជាមូលដ្ឋាននៃនីតិរដ្ឋ។ ការវិវត្តន៍នេះរួមមាន អង្គការសហប្រជាជាតិបានទទួលយកនូវនិយមន័យនៃពាក្យនីតិរដ្ឋ ទាក់ទងនឹងទស្សនៈសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ និងការបញ្ចូលនីតិរដ្ឋនៅក្នុងធម្មនុញ្ញអាស៊ាន ទៅជាផ្នែកមួយនៃចលនាឆ្ពោះទៅកាន់សហគមន៍អាស៊ានរួម ដោយផ្អែកលើច្បាប់ និងគុណតម្លៃ។

៧. ជាបន្ទាប់យើងនឹងពិចារណាពីការវិវត្តន៍ថ្មីៗទាំងនេះ។

<u>ឃ- នីតិរដ្ឋ សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ៖ គោលការណ៍ដែលពាក់ព័ន្ធ និងពង្រឹងការអនុវត្តន៍ទៅវិញទៅមក</u>

១. នៅឆ្នាំ ២០០៤ ក្រោមកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការអនុវត្តន៍ និងការយល់ដឹងពីនីតិរដ្ឋជារួម លោក **កូហ្វី អាណាន់** ដែលជាអគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្តល់និយមន័យដូចខាងក្រោមថា ៖

> *["នីតិរដ្ឋ"] គឺសំដៅលើគោលការណ៍អភិបាលកិច្ច ដែលជនគ្រប់រូប ស្ថាប័ន នីតិបុគ្គលវិស័យសាធារណៈ ឯកជន រួមទាំងរដ្ឋ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដែលកំពុងអនុវត្ត ដោយស្មើភាព ដោយឯករាជ្យ និងស្របទៅនឹងបទដ្ឋាន និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ជាគោលការណ៍ ត្រូវធ្វើឲ្យស្របនឹងច្បាប់កំពូល៖ភាពស្មើគ្នាចំពោះមុខច្បាប់ ការទទួលខុសត្រូវចំពោះច្បាប់ ការអនុវត្តន៍ច្បាប់ប្រកបដោយភាពត្រឹមត្រូវ ការបែងចែកអំណាចច្បាស់លាស់ ការចូលរួមក្នុងការសម្រេចចិត្តស្មេរភាពនៃច្បាប់ ជៀសវាងនូវភាពលំអៀង និងតម្លាភាពនៃច្បាប់ និងដំណើការនីតិវិធី។*[xxx]

២. ទ្រឹស្តីរបស់លោក **កូហ្វី អាណាន់** ត្រូវបានអភិវឌ្ឍបន្ថែមនៅក្នុងឯកសារណែនាំចុងក្រោយរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីជំនួយយុទ្ធសាស្ត្រពង្រឹងការអនុវត្តន៍នីតិរដ្ឋ (UN S-G's Guidance Note) ៖

*"នីតិរដ្ឋ គឺជាគោលការណ៍អភិបាលកិច្ច ដែលមនុស្សគ្រប់រូប ស្ថាប័ន នីតិបុគ្គល វិស័យសាធារណៈ ឯកជន រួមទាំងរដ្ឋត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ដែលកំពុងអនុវត្តដោយស្មើភាព ឯករាជ្យ ដែលស្របទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ករណីនេះ ក៏តម្រូវផងដែរនូវវិធានការណ៍ ដើម្បីធានានូវគោលការណ៍ច្បាប់កំពូល ដូចជា ភាពស្មើគ្នាចំពោះមុខច្បាប់ និងការទទួលខុសត្រូវចំពោះមុខច្បាប់ ការអនុវត្តន៍ច្បាប់ប្រកបដោយភាពត្រឹមត្រូវ ការបែងចែកអំណាចច្បាស់លាស់ ការចូលរួមក្នុងការសម្រេចចិត្តស្មេរភាពនៃច្បាប់ ការជៀសវាងនូវភាពលំអៀង និងតម្លាភាពនៃដំណើរការនីតិវិធី និងច្បាប់។ យុត្តិធម៌ គឺជាឧត្តមភាពស្នូលនៃការទទួលខុសត្រូវ និងភាពត្រឹមត្រូវក្នុងការការពារ និងការទប់ស្កាត់ និងការដាក់ទណ្ឌកម្មដោយមិនត្រឹមត្រូវ។ ការប្រើប្រាស់ពាក្យនេះ គឺអាស្រ័យទៅលើយន្តការតុលាការ ទំនៀមទម្លាប់ និងប្រពៃណី" (ពឹងផ្អែកទៅវិញទៅមក)។*[xxxi]

៣. ឯកសារណែនាំរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានបញ្ជាក់ពីទំនាក់ទំនងទៅវិញទៅមករវាងប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្ស។

*"នៅក្នុងបរិបទសិទ្ធិមនុស្ស នីតិរដ្ឋ និងប្រជាធិបតេយ្យ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត និងបង្កើតការអនុវត្តន៍ទៅវិញទៅមក ហើយគោលការណ៍ទាំងពីរនេះ គឺជាផ្នែកមួយជាសកល ដែលមានគុណតម្លៃ និងជាគោលការណ៍នៃអង្គការសហប្រជាជាតិ។"*[xxxii]

៤. ការបញ្ជាក់ថាទ្រឹស្តីមុនពិតជាត្រឹមត្រូវ លោក **បាន់ គីមូន** ដែលជាអគ្គលេខាធិការអង្គការសហប្រជាជាតិ បានលើកឡើងជាថ្មីថា ការគោរពនីតិរដ្ឋ គឺ "សំដៅលើការគោរពសិទ្ធិមនុស្ស និងមានឆន្ទៈបើកទូលាយពីភាពខុសប្លែកគ្នា"។ លោកបានបន្តសង្កត់ធ្ងន់ថា ត្រូវយល់ដឹងឲ្យបានច្បាស់អំពីទស្សនៈនេះ និងស្របទៅតាមកាលវេលា ជាពិសេស នៅពេលដែលភាពខុសប្លែកនៃតម្រូវការរបស់មនុស្ស ដូចជា "ទាក់ទងនឹងបញ្ហាជាមូលដ្ឋាន បញ្ហាវប្បធម៌ និងជំនឿ។"[xxxiii]

៥. ទ្រឹស្តីរបស់លោក **កូហ្វី អាណាន់** និងទ្រឹស្តីជាបន្តបន្ទាប់ (ទ្រឹស្តីរួមរបស់អង្គការសហប្រជាជាតិ) គឺពិតជាមានសារៈសំខាន់នៅក្នុងទិដ្ឋភាពជាច្រើន។

៦. ជាដំបូង នៅពេលដែលទ្រឹស្តីនៃនីតិរដ្ឋត្រូវបានលើកឡើងដោយអង្គការសហប្រជាជាតិ គឺមិនទាន់មានន័យគ្រប់គ្រាន់នៅឡើយទេ[xxxiv] ដោយបានបង្ហាញពីធាតុជាមូលដ្ឋាន រួមមាន រចនាសម្ព័ន្ធ ការអនុវត្តន៍ ការវាយតម្លៃ និងការកែទម្រង់ច្បាប់ពាក់ព័ន្ធនឹងគ្រឹះស្ថាននៅពិភពលោក។ ងាកចេញពីភាពខុសគ្នានៃទស្សនៈដើម និងទស្សនៈស៊ីជម្រៅនៃពាក្យនីតិរដ្ឋ ដូចបានលើកឡើងក្នុងកថាខណ្ឌទី២៧ខាងលើ ទ្រឹស្តីនេះត្រូវបានរួមបញ្ចូលធាតុជាក់លាក់ រួមមានដូចជា សមភាព ភាពទទួលខុសត្រូវ ការជៀសវាងនូវភាពលំអៀងនៃច្បាប់ បទដ្ឋានគតិយុត្តិ និងសិទ្ធិមនុស្ស ទោះបីជាការរក្សាទុកនូវទស្សនៈទំនៀមទម្លាប់ ដូចជា ឧត្តមភាពនៃច្បាប់។

៧. ទី២ ៖ ទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិត្រូវបានគាំទ្រពាសពេញពិភពលោក ហើយធ្វើឲ្យនីតិរដ្ឋ និងសិទ្ធិមនុស្សកាន់តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត។ នៅក្នុងកិច្ចប្រជុំកំពូលពិភពលោកកាលពីឆ្នាំ ២០០៥ ប្រទេសជាសមាជិកទាំង ១៩២ប្រទេស រួមទាំង ប្រជាជាតិអាស៊ាន បានប្តេជ្ញាចិត្ត "ចូលរួមសកម្មក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស នីតិរដ្ឋ និងប្រជាធិបតេយ្យ" ដោយទទួលស្គាល់ថា [គោលការណ៍ទាំងនេះ] មានទំនាក់ទំនង និងជួយពង្រឹងការអនុវត្តន៍ទៅវិញទៅមក ដូច្នេះ គុណតម្លៃ និងគោលការណ៍ស្នូលនៃទ្រឹស្តីរបស់អង្គការសហប្រជាជាតិបានក្លាយជាគោលការណ៍សកល។ អង្គការសហប្រជាជាតិលើគ្រប់វិស័យ ត្រូវតែលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានស្របទៅតាមមុខងាររបស់ខ្លួន។[xxxv]

៨. ទី៣ ៖ ទ្រឹស្តីរបស់អង្គការសហប្រជាជាតិបានទទួលស្គាល់ថា នីតិរដ្ឋ គឺពិតជា "មានទំនាក់ទំនង និងជួយពង្រឹងការអនុវត្តន៍ទៅវិញទៅមក" ដូចគ្នានឹងសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ មានន័យថា គោលការណ៍ទាំងនេះ ត្រូវពិនិត្យមើលស្របគ្នា គឺមិនអាចបោះបង់ទ្រឹស្តីណាមួយនោះទេ ដូចជាទស្សនៈដំបូងរបស់នីតិរដ្ឋ។ គោលការណ៍ទាំងនេះមិនត្រឹមតែពាក់ព័ន្ធ និងរួមបញ្ចូលគ្នាប៉ុណ្ណោះទេ ប៉ុន្តែពិតជាបានជួយពង្រឹងការអនុវត្តន៍គ្នាទៅវិញទៅមក ហេតុដូច្នេះពិតជាមានសារៈសំខាន់ណាស់។

៩. ទី៤ ៖ លោក Brian Tomanaha បានកត់សម្គាល់ថា ទ្រឹស្តីនីតិរដ្ឋដែលផ្តល់ដោយអង្គការសហប្រជាជាតិ ដែលថា "មានប្រភពមកពីភាពស្របច្បាប់ សិទ្ធិបុគ្គល និងប្រជាធិបតេយ្យ" គឺតម្រូវការតាមដាន និងត្រួតពិនិត្យ នោះទើបបង្ហាញពីសារៈសំខាន់នៃនីតិរដ្ឋ។ ទស្សនៈរួមនៃនីតិរដ្ឋបានបង្ហាញពីការអាចទប់ស្កាត់ការអនុវត្តន៍មិនត្រឹមត្រូវនៃអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិប្បញ្ញត្តិ ដោយមិនឲ្យរំលោភដល់សិទ្ធិបុគ្គល និងជ្រៀតជ្រែកទៅក្នុងអំណាចរបស់តុលាការ ប្រសិនបើការតាក់តែងច្បាប់បែបប្រជាធិបតេយ្យ ពុំបានពិចារណាពីភាពត្រឹមត្រូវនៃសេចក្តីសម្រេចរបស់តុលាការ។[xxxvi]

១០. ទី៥ ៖ ទ្រឹស្តីរបស់អង្គការសហប្រជាជាតិបានបែងចែកពីភាពខុសគ្នារវាង "នីតិរដ្ឋ" និង "យុត្តិធម៌" ។ នីតិរដ្ឋ គឺផ្តោតសំខាន់ទៅលើ "គោលការណ៍អភិបាលកិច្ច" ចំណែកឯ "ពាក្យយុត្តិធម៌" គឺសំដៅទៅលើ "ទស្សនៈទទួលខុសត្រូវ និងភាពត្រឹមត្រូវ"។ ដូច្នេះ ការកំណត់ថ្មីនេះ បានជួយឲ្យជៀសផុតនូវភាពលំបាកក្នុងការកំណត់និយមន័យរាប់មិនអស់របស់ពាក្យនីតិរដ្ឋដែលបានរៀបរាប់ខាងលើ។ នីតិរដ្ឋត្រូវបានលើកឡើងដើម្បីជួយដោះស្រាយ "បញ្ហាដែលបានជួបប្រទះនៅក្នុងសកលោក"។[xxxvii]

១១. ជាទីបញ្ចប់ ទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិបានបង្ហាញពីចំណុចសំខាន់នៃអភិបាលកិច្ចល្អ និងមិនមែនជាឈ្នាន់នៃទស្សនៈនយោបាយ ដោយចាត់ថ្នាក់អាស្រ័យទៅលើកម្រិតនៃរបៀបគ្រប់គ្រងរដ្ឋដូចគ្នានឹងប្រទេសលោកខាងលិច (ដូចដែលបានរៀបរាប់ក្នុងកថាខណ្ឌទី២៧ ខាងលើ)។ ជាក់ស្តែង ទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិបានព្យាយាមជៀសវាងនូវការចាត់ថ្នាក់ ដែលធ្វើឲ្យប៉ះពាល់ដល់សញ្ញាណផ្សេងគ្នា ដូចជា វប្បធម៌ និងជំនឿ ដែលនេះ គឺជាឆ្លុះបញ្ចាំងពីការគោរពសិទ្ធិមនុស្ស។

**ង- នីតិរដ្ឋ សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ៖ ការតាក់តែងធម្មនុញ្ញអាស៊ានថ្មី**

១. ទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិត្រូវបានកំណត់ក្នុងធម្មនុញ្ញអាស៊ានថ្មី ដែលបានផ្តល់សច្ចាប័នដោយប្រទេសទាំង១០ នៅអាស៊ាន។

២. ជាប្រវត្តិសាស្រ្ត "អាស៊ានពុំធ្លាប់ជាប់ពាក់ព័ន្ធនឹងច្បាប់អន្តរជាតិ ឬសន្ធិសញ្ញានានានោះទេ អាស៊ានត្រូវបានកំណត់ថា ជាបណ្តុំជាតិសាសន៍នៅលើដែនដីមួយ ដែលប្រតិបត្តិការណ៍ដោយផ្អែកលើការយោគយល់គ្នាជាបណ្តោះអាសន្ន និងដំណើរការដោយមិនផ្លូវការណ៍ ជាជាងក្នុងក្របខណ្ឌគតិយុត្តិ"។[xxxviii] គួរឲ្យកត់សម្គាល់នៅឆ្នាំ២០០១ មានការវិវត្តន៍ចង់ក្រងសន្ធិសញ្ញាអាស៊ាន ផ្តោតសំខាន់លើពាណិជ្ជកម្ម និងការវិនិយោគ។ លោក Rodolfo Severino ដែលជាអតីតអគ្គលេខាធិការអាស៊ាន បានធ្វើការវាយតម្លៃកាលពីឆ្នាំ២០០១ថា "ការវិវត្តន៍វិធានគ្រប់គ្រងសេដ្ឋកិច្ចតំបន់ គឺពិតជាអាចពន្លាតវិសាលភាពទៅលើផ្នែកផ្សេងៗទៀតពាក់ព័ន្ធនឹងប្រតិបត្តិការណ៍នៅអាស៊ាន នាពេលអនាគត អាស៊ានអាចនឹងក្លាយតំបន់មួយ ដែលមិនត្រឹមតែការជួយគ្នាលើផ្នែកសេដ្ឋកិច្ច។"[xxxix]

៣. យើងយល់ឃើញថា ការព្យាករណ៍របស់លោក Severino មកដល់ពេលនេះពិតជាត្រឹមត្រូវ។ ការអនុម័តធម្មនុញ្ញអាស៊ាននៅក្នុងកិច្ចប្រជុំកំពូលអាស៊ានកាលពី ខែវិច្ឆិកា ឆ្នាំ២០០៧ បានបង្ហាញពីការវិវត្តន៍របស់អាស៊ានទៅជា "អង្គការនយោបាយទោលមួយ" និងបានបង្ហាញពីការប្តេជ្ញាចិត្ត ចំពោះការលើកកម្ពស់ការអនុវត្តន៍នីតិរដ្ឋ ដែលយកគំរូតាមទ្រឹស្តីរបស់អង្គការសហប្រជាជាតិ។ ធម្មនុញ្ញអាស៊ានត្រូវបានរៀបចំឲ្យទៅជាច្បាប់ ដោយគោរពតាមនីតិរដ្ឋ (នាពេលបច្ចុប្បន្នមានទំនាក់ទំនងជិតស្និតទៅនឹងសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ)។ គោលបំណង និងគោលការណ៍ស្នូលរបស់អាស៊ាន ត្រូវបានប្រទេសជាសមាជិកអាស៊ានទាំងអស់ប្តេជ្ញាយកទៅអនុវត្ត។

៤. ជាពិសេស នៅក្នុងអារម្ភកថានៃធម្មនុញ្ញអាស៊ានបានចែងថា រដ្ឋជាសមាជិករបស់អាស៊ានត្រូវគោរពតាម ៖

> *"គោលការណ៍ប្រជាធិបតេយ្យ (នីតិរដ្ឋ និងអភិបាលកិច្ចល្អ) ការគោរព និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។"*[xl]

៥. ករណីដូចគ្នានេះ មាត្រា ១(៧) នៃធម្មនុញ្ញអាស៊ានបានចែងថា កម្មវត្ថុ និងគោលបំណងរបស់អាស៊ានគឺ ៖

> *"ការពង្រឹងប្រជាធិបតេយ្យ លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ លើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលទាក់ទងនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋជាសមាជិកអាស៊ាន"។*[xli]

៦. សំខាន់ជាងនេះ ធម្មនុញ្ញអាស៊ានពុំបានលើកយកទស្សនៈនីតិរដ្ឋដាច់ដោយឡែកនោះទេ គឺបានផ្សាភ្ជាប់ទៅនឹងពាក្យ "អភិបាលកិច្ចល្អ" ដែលចំណុចនេះ គឺស្រដៀងគ្នាទៅនឹងទ្រឹស្តីនៃនីតិរដ្ឋរបស់អង្គការសហប្រជាជាតិ។

៧. ធម្មនុញ្ញអាស៊ាន និងការប្តេជ្ញាចិត្តចំពោះនីតិរដ្ឋ គឺជាដំណាក់កាលវិវត្តន៍ដ៏អស្ចារ្យរបស់សមាជិកអាស៊ានទាំង ១០។ លោក Severino បានពន្យល់ថា វាពិតជាមានសារៈសំខាន់ដែលទស្សនៈនីតិរដ្ឋត្រូវបានបញ្ចូលទៅក្នុងធម្មនុញ្ញអាស៊ាន ៖

*"ជាដំបូង បទដ្ឋានរបស់អាស៊ាន គឺកម្រិតត្រឹមឥរិយាបថរបស់រដ្ឋជាសមាជិកចំពោះប្រជាពលរដ្ឋរបស់ខ្លួន រួមមាន ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន អភិបាលកិច្ចល្អ រដ្ឋាភិបាលអាស្រ័យរដ្ឋធម្មនុញ្ញ នីតិរដ្ឋ និងយុត្តិធម៌សង្គមប៉ុណ្ណោះ។*[xlii]

**<u>ច- នីតិរដ្ឋ សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ៖ សរសរស្តម្ភទាំងបី នៃសហគមន៍អាស៊ានផ្អែកលើច្បាប់ គុណតម្លៃ និងបទដ្ឋានរួម</u>**

១. ធម្មនុញ្ញអាស៊ានពុំត្រឹមតែជាឯកសារដែលមានកំណត់អំពីនីតិរដ្ឋ និងអភិបាលកិច្ចល្អ ចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ។ នៅឆ្នាំ២០០៩ ទំនាក់ទំនងនេះបានលើកឡើងក្នុងឯកសារណែនាំមួយសម្រាប់សហគមន៍អាស៊ាន ដែលជាការឯកភាពបង្កើតឡើងដោយប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល មានឈ្មោះថា សហគមន៍សន្តិសុខនយោបាយអាស៊ាន (ASEAN Roadmap) នៅឆ្នាំ២០១៥៖

*"សហគមន៍សន្តិសុខនយោបាយអាស៊ាន គឺត្រូវលើកកម្ពស់ការអភិវឌ្ឍន៍នយោបាយដោយគោរពតាមគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិបាលកិច្ចល្អ ព្រមទាំងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចដែលមានចែងក្នុងធម្មនុញ្ញអាស៊ាន។*

*ចំណុចនេះអាចជាយុទ្ធសាស្ត្រសម្រាប់រដ្ឋជាសមាជិកអាស៊ានអាចបន្តទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការណ៍កាន់តែជិតស្និទ្ធ ដើម្បីពង្រឹងបទដ្ឋានរួម និងបង្កើតយន្តការរួមឲ្យសម្រេចបានតាមគោលដៅ និងគោលបំណងរបស់អាស៊ានក្នុងវិស័យសន្តិសុខ និងនយោបាយ"។*[xliii]

២. ផែនការណែនាំរបស់អាស៊ាន បានកំណត់អំពីអភិបាលកិច្ចល្អ និងនីតិរដ្ឋប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលជាសរសរស្តម្ភមូលដ្ឋានសម្រាប់បង្កើត "សហគមន៍ ដែលផ្អែកលើច្បាប់ គុណតម្លៃ និងបទដ្ឋានរួម" ៖

*"កិច្ចសហប្រតិបត្តិការណ៍អាស៊ានក្នុងការអភិវឌ្ឍន៍នយោបាយ ធ្វើឡើងក្នុងគោលបំណងពង្រឹងប្រជាធិបតេយ្យ ការលើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលពាក់ព័ន្ធនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋជាសមាជិកអាស៊ាន ដោយបង្កើតសហគមន៍មួយ ដែលផ្អែកលើច្បាប់ គុណតម្លៃ និងបទដ្ឋានរួម។ ការរៀបចំ និងការបង្កើតបទដ្ឋានអាស៊ាន គឺមានបំណងសម្រេចឲ្យបាននូវការគោរពច្បាប់ការប្រតិបត្តិល្អ ក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន សម្របសម្រួល និងពង្រឹងសាមគ្គីភាពនៅអាស៊ាន ដោយភាពជិតស្និទ្ធ*

*និងសុខដុម ព្រមទាំងការរួមចំណែកក្នុងការកសាងសន្តិភាព ប្រជាធិបតេយ្យដោយបើកទូលាយ ដោយការចូលរួម និងមានតម្លាភាពនៅអាស៊ីអាគ្នេយ៍”។*[xliv]

៣. កិច្ចប្រឹងប្រែងនេះកំពុងស្ថិតនៅក្នុងដំណើរការ ការរៀបចំជាមូលដ្ឋាននូវក្របខណ្ឌស្ថាប័នក្នុងការជួយសម្របសម្រួលលំហូរព័ត៌មានដោយសេរី ផ្អែកតាមច្បាប់ជាតិ និងបទប្បញ្ញត្តិរបស់ប្រទេសនីមួយៗ។ ការទប់ស្កាត់ ការប្រឆាំងនឹងអំពើពុករលួយ និងកិច្ចសហប្រតិបត្តិការណ៍ ដើម្បីពង្រឹងនីតិរដ្ឋ ប្រព័ន្ធយុត្តិធម៌ និងហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងអភិបាលកិច្ចល្អ។[xlv] នីតិរដ្ឋត្រូវបានទទួលស្គាល់ថា គឺជាការជួយពង្រឹងលទ្ធិប្រជាធិបតេយ្យ ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សជាមូលដ្ឋាន។

៤. យន្តការសំខាន់រួមមួយ ដែលបង្កើតឡើងដើម្បីសម្រេចឲ្យបាននូវលក្ខខណ្ឌនៃ “ការគោរពនីតិរដ្ឋ អភិបាលកិច្ចល្អ គោលការណ៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាលផ្អែកលើរដ្ឋធម្មនុញ្ញ”[xlvi] គឺគណកម្មការសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន។ ផ្តើមចេញពីទស្សនៈសិទ្ធិមនុស្សបែបគ្រឹះសាសនា យោងតាមមាត្រា ១៤ នៃធម្មនុញ្ញអាស៊ាន បាននាំឆ្ពោះឲ្យមានការបង្កើតនូវគណកម្មការប្រឹក្សាយោបល់ថ្មីមួយទៀត ដែលមានឈ្មោះថា គណៈកម្មការអន្តររដ្ឋទទួលបន្ទុកសិទ្ធិមនុស្ស (AICHR)។

៥. ក្នុងនាមជាសមាជិកនៃក្រុមការងារជាន់ខ្ពស់អាស៊ាន (HLTF) ទទួលបន្ទុកកសាង និងតាក់តែងសេចក្តីព្រាងធម្មនុញ្ញអាស៊ានបានសង្កត់ធ្ងន់ថា ៖

*“ដំបូងឡើយ ‘សិទ្ធិមនុស្ស’ ត្រូវបានចាត់ទុកថាជា ‘ការហាមប្រាម’ នៅអាស៊ាន និងពុំមែនជាប្រធានបទដែលត្រូវលើកយកមកពិភាក្សាលម្អិតនោះទេ។ ដោយមូលហេតុនេះ ការលើកយកមកពិភាក្សាក្នុងក្រុមការងារជាន់ខ្ពស់ គឺជាការវិវត្តន៍ដ៏ប្រសើរសម្រាប់អាស៊ាន។ សេចក្តីសម្រេចចុងក្រោយនៃបញ្ហានេះ រដ្ឋជាសមាជិកបានលើកពីការកើនឡើងនៃការទទួលស្គាល់សារៈសំខាននៃសិទ្ធិមនុស្ស សុខុមាលភាពទូទៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ព្រមទាំងស្របគ្នាទៅនឹងទស្សនៈក្នុងការប្រែក្លាយអាស៊ានទៅជាអង្គការដែលផ្តល់តម្លៃលើពលរដ្ឋជាធំ។”*[xlvii]

៦. អាស៊ានក៏បានផ្តួចផ្តើមនូវការវិវត្តន៍ចំពោះ “ការផ្តល់តម្លៃលើពលរដ្ឋជាធំ” ដូចជា ការការពារសិទ្ធិស្ត្រី និងកុមារ ព្រមទាំងការពារសិទ្ធិជនទេសន្តរប្រវេសន៍។ នៅឆ្នាំ២០០៧ ប្រមុខអាស៊ានបានចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិជនទេសន្តរប្រវេសន៍។ នៅក្នុងកិច្ចប្រជុំកំពូលរបស់អាស៊ានលើកទី ១៥ កាលពីឆ្នាំ២០០៩ បានអនុម័តលក្ខខណ្ឌសម្រាប់គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (“ACWC”) ដែលគណកម្មការនេះ បានបង្កើតចេញជារូបរាងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ១៦ នៅខែមេសា ឆ្នាំ២០១០ និងមានវត្តមានរួមគ្នាជាមួយគណៈកម្មការអន្តររដ្ឋទទួលបន្ទុកសិទ្ធិមនុស្ស AICHR នាពេលបច្ចុប្បន្ន។

៧. បើពិនិត្យទៅលើទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិ និងឯកសារគន្លឹះរបស់ធម្មនុញ្ញអាស៊ានដូចបានលើកឡើងខាងលើអាស៊ានពិតជាមានការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់ ទាំងការបង្កើតច្បាប់ និងដំណើរការរបស់វាចាប់តាំងពីឆ្នាំ២០០៧ ដោយបង្ហាញថា នីតិរដ្ឋ និងអភិបាលកិច្ចល្អ ព្រមទាំងសិទ្ធិមនុស្សមានទំនាក់ទំនង និងជួយពង្រឹងការអនុវត្តន៍គ្នាទៅវិញទៅមក ដែលស្ថិតក្នុងគុណតម្លៃ និងបទដ្ឋានរួមនៃសហគមន៍អាស៊ាន និងតម្រូវឲ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ត្រូវលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានស្របទៅតាមភារកិច្ចរួមរបស់អាស៊ាន។

## ខ. ការសិក្សាអំពីនីតិរដ្ឋនៅអាស៊ាន

ក- គោលការណ៍ស្នូលបួនអំពីនីតិរដ្ឋនៅអាស៊ាន

១. ទាញចេញពីការទទួលស្គាល់ជាទូទៅនូវទ្រឹស្តីនីតិរដ្ឋរបស់អង្គការសហប្រជាជាតិ និងការប្រើប្រាស់ធម្មនុញ្ញអាស៊ាន ព្រមទាំងការវិវត្តន៍ដែលពាក់ព័ន្ធនានា គឺជាគោលការណ៍សម្រាប់ការវិភាគ។ យើងបានកំណត់នូវគោលការណ៍ស្នូលបួនអំពីនីតិរដ្ឋ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅអាស៊ាន គឺមានលក្ខណៈសំខាន់ និងជាផ្លូវការណ៍។

២. គោលការណ៍ស្នូលទី ១ បានចោទឡើង ថាតើរដ្ឋាភិបាលបានបង្កើតច្បាប់មួយ ដែលស្ថិតក្រោមឋានានុក្រមនៃច្បាប់រដ្ឋធម្មនុញ្ញ និងប្បញ្ញត្តិនានា ដែលកំណត់ការដាក់បញ្ចូលមន្ត្រី និងភ្នាក់ងាររបស់ខ្លួន។

៣. គោលការណ៍ស្នូលទី ២ បានចោទសួរ ថាតើច្បាប់ និងនីតិវិធីក្នុងការចាប់ខ្លួន ការឃុំខ្លួន និងដាក់ទណ្ឌកម្មត្រូវបានផ្សព្វផ្សាយជាសារណៈដោយស្របតាមគតិច្បាប់ និងមិនលំអៀង។ គោលការណ៍ស្នូលនេះគឺពាក់ព័ន្ធនឹងការអនុវត្តន៍ក្រមព្រហ្មទណ្ឌ ដើម្បីលើកកម្ពស់ និងការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានដូចជា សេរីភាព កិត្យានុភាពជាសារវន្តែ សន្តិសុខបុគ្គល និងដំណើរការនីតិវិធីច្បាប់ឲ្យបានត្រឹមត្រូវ។

៤. គោលការណ៍ស្នូលទី ៣ ចោទសួរ ថាតើបុគ្គលម្នាក់ៗមានសិទ្ធិទទួលបានយុត្តិធម៌ដូចដែលបានកំណត់នៅក្នុងច្បាប់ ដោយត្រឹមត្រូវ មានប្រសិទ្ធភាព និងស្មើភាព។ គោលការណ៍នេះ គឺបារម្ភថាតើច្បាប់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងបានអនុវត្តដោយស្មើភាពគ្នា និងថាតើបុគ្គលម្នាក់ៗមានសិទ្ធិទទួលបានដំណើរការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

៥. គោលការណ៍ស្នូលទី៤ចំណោទថាតើយុត្តិធម៌ត្រូវបានគ្រប់គ្រងដោយស្ថាប័ន ដែលមានឯករាជ្យ មិនលំអៀង និងប្រកបដោយសមត្ថភាព។គោលការណ៍ស្នូលទី ៣ គឺពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានយុត្តិធម៌ ចំណែកឯគោលការណ៍ស្នូលទី ៤ គឺពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់តុលាការ និងស្ថាប័នយុត្តិធម៌ដទៃទៀត ថាតើមានលក្ខណៈត្រឹមត្រូវ ឯករាជ្យ និងមិនលំអៀង។

៦. តាមការពិចារណាទៅលើគោលការណ៍ស្នូលទាំងបួន បានបង្ហាញថា ពិតជាបានបង្កើតមូលដ្ឋានមួយក្នុងការអនុវត្តន៍នីតិរដ្ឋនៅអាស៊ាន ដែលនេះជាជោគជ័យដ៏អស្ចារ្យ។ អនុសាសន៍នានាពាក់ព័ន្ធនឹងគោលនយោបាយ អាចនឹងត្រូវបានកំណត់នាពេលដ៏ខ្លីខាងមុខ ហើយការវិវត្តន៍របស់ប្រទេសជាសមាជិកអាស៊ាននីមួយៗ អាចនឹងធ្វើការវាស់ស្ទង់បាន។ របាយការណ៍ប្រចាំប្រទេសនីមួយៗ គឺពិតជាបានឆ្លើយតបទៅនឹងសូចនាករ ដែលបានលើកឡើងពីគោលការណ៍ស្នូលទាំង៤។ ទិដ្ឋភាពនីតិរដ្ឋដ៏ត្រឹមត្រូវ គឺត្រូវពិនិត្យទៅលើបទដ្ឋានច្បាប់ និងការអនុវត្តន៍ជាក់ស្តែង ។

៧. គោលការណ៍ស្នូលទាំងបួន ពុំមែនឥតប្រយោជន៍ ឬជាសូចនាករ ដែលឆ្លាក់តែទៅលើសិលាចារិកនោះទេ។ បន្ថែមលើនេះ យើងសង្ឃឹមថា គោលការណ៍ និងសូចនាករទាំងនេះ នឹងត្រូវបានត្រួតពិនិត្យឡើងវិញ ដោយផ្អែកទៅលើទិន្នន័យដែលបានសម្រិតសម្រាំង។

## <u>ខ- តារាងរចនាសម្ព័ន្ធអំពីនីតិរដ្ឋអាស៊ាន</u>

១. យើងបានកំណត់នូវលទ្ធផលនៃឯកសារសិក្សាជាមូលដ្ឋាននេះ ត្រឹមកម្រិតតារាងនីតិរដ្ឋនៅអាស៊ាន។ តារាងនេះធ្វើឡើងមិនត្រឹមតែកំណត់នូវទិន្នន័យសង្ខេប "ដើម្បីចាត់ចំណាត់ថ្នាក់" នៃការអនុវត្តន៍នៅក្នុងប្រទេសនីមួយៗនោះទេ។ ជាក់ស្តែង តារាងនេះ គឺបានបង្ហាញពីលទ្ធផលបឋម ដែលពាក់ព័ន្ធនឹងគោលការណ៍ស្នូលទាំងបួន និងការអនុវត្តន៍នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងមនុស្សធម៌។ អ្នកស្រាវជ្រាវរបស់យើងបានធ្វើការវិភាគលើអត្ថបទ និងទិន្នន័យនានាដែលប្រមូលបាន (មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ) នៃរបាយការណ៍ប្រចាំប្រទេសនីមួយៗ។ <u>***កំណត់សម្គាល់***</u> និងសេចក្តីសន្និដ្ឋានលម្អិត គឺបានបង្ហាញនៅក្នុងផ្នែកជាបន្តបន្ទាប់នៅក្នុងរបាយការណ៍នេះ។

## <u>គ- គោលការណ៍ស្នូលទី១៖រដ្ឋាភិបាល និងមន្ត្រីនានាទទួលខុសត្រូវចំពោះមុខច្បាប់</u>

១. គោលការណ៍ស្នូលនៃនីតិរដ្ឋគឺថាពុំមានបុគ្គលណាម្នាក់មានឋានុក្រមខ្ពស់ជាងច្បាប់ រួមទាំង រដ្ឋាភិបាល និងមន្ត្រីនានា។ គោលការណ៍នេះបានដាក់ឲ្យទៅជាច្បាប់ ដែលបុគ្គលគ្រប់រូបត្រូវតែគោរពតាម។ ការបែងចែកអំណាចនៃអង្គទាំងបី គឺជាការព្យាករណ៍ដ៏មានសារសំខាន់។ រដ្ឋាភិបាលក៏ត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់។[xlviii]

២. ដូចមានបង្ហាញក្នុងតារាងនីតិរដ្ឋអាស៊ាន ប្រទេស ៨ ក្នុងចំណោមប្រទេសទាំង ១០ កំពុងអនុវត្តច្បាប់ដែលបានកំណត់ពីការបែងចែកអំណាច និងអនុញ្ញាតឲ្យតុលាការ និងស្ថាប័នយុត្តិធម៌នាំយកមន្ត្រីរដ្ឋាភិបាល និងភ្នាក់ងារនានាឲ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន។

៣. ទោះបីជាខ្សែរាជវង្សក៏តម្រូវឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ផងដែរនៅប្រទេសម៉ាឡេស៊ី។ នៅប្រទេសប្រ៊ុយណេ លើកលែងតែស្តេច **ស៊ុល តង់** ដែលជាបុគ្គលមានអំណាចផ្តាច់មុខ ច្បាប់អនុញ្ញាតឲ្យមានការកាត់ទោសលើមន្ត្រីរដ្ឋាភិបាល ចំពោះការប្រព្រឹត្តកំហុសភារកិច្ច។ ចំណែកនៅប្រទេសសិង្ហបុរី មានច្បាប់ដ៏តឹងរឹងក្នុងការដាក់ទោសចំពោះអំពើពុករលួយ និងការវិនិច្ឆ័យខុសរបស់អាជ្ញាធរសាធារណៈ ព្រមទាំងអនុវត្តចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់នានា។ ក្រោមជំនួយឧបថម្ភពីសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ សេចក្តីព្រាងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ត្រូវបានរៀបចំឡើង។ ច្បាប់នេះត្រូវបានចាត់ទុកថា មានលក្ខណៈទំនើប និងបានកំណត់យ៉ាងច្បាស់ពីការបែងចែកអំណាច និងជាទ្រឹស្តីមានការត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល។

៤. ក្រោមការគ្រប់គ្រងដោយអំណាចយោធាជាច្រើនទសវត្សរ៍ ប្រទេសភូមាបានប្រែក្លាយទៅជាប្រទេសដែលគ្រប់គ្រងរដ្ឋអាស្រ័យដោយរដ្ឋធម្មនុញ្ញ។ បទប្បញ្ញត្តិសម្រាប់ផ្តន្ទាទោសមន្ត្រីរដ្ឋាភិបាល រួមមានប្រធានាធិបតី អនុប្រធានាធិបតី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការ និងចៅក្រមនានាត្រូវបានកំណត់។ ស្រដៀងគ្នានេះ នៅប្រទេសវៀតណាម យន្តការកាត់ទោសរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៅរដ្ឋសភា ក៏លេចចេញជារូបរាង ទោះបីជាមានការមិនពេញចិត្ត និងមានការជំទាស់ជាច្រើន ត្រូវបានលើកឡើងនៅសភាជាតិ។

៥. ជាការពិតណាស់យើងត្រូវធ្វើការបែងចែកឲ្យបានច្បាស់រវាងរដ្ឋធម្មនុញ្ញ ឬច្បាប់ និងបញ្ហាដែលបានកើតឡើងជាក់ស្តែង។ ប្រព័ន្ធនៃការបែងចែកអំណាចនៅប្រទេសភូមា ដែលទើបមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងបទដ្ឋានគតិយុត្តិនានា គឺមានឥទ្ធិពលតិចតួច ដោយសារតែរដ្ឋាភិបាលអនុវត្តដោយផ្អែកតាមជីវភាពប្រចាំថ្ងៃ។ នៅក្នុងប្រទេសជាច្រើន អ្នកសង្កេតការណ៍បានលើកជាចំណោទ ថាតើបុគ្គលដែលមានឋានៈនៅក្នុងជួររដ្ឋាភិបាល អាចរត់គេចពីការស៊ើបអង្កេត ឬការចោទប្រកាន់ដោយនិទណ្ឌភាពទៅទីកន្លែងណា? នៅប្រទេសប្រ៊ុយណេ ទិន្នន័យពីការស៊ើបអង្កេតចំពោះការប្រព្រឹត្តកំហុសរបស់មន្ត្រីរដ្ឋាភិបាល គឺពុំអាចរកបានឡើយ ព្រោះពុំមានកំណត់ត្រាពីករណីនេះ។ ដូច្នេះ ពិតជាពិបាកក្នុងការលើកយកតួលេខឲ្យបានច្បាស់លាស់ និងត្រឹមត្រូវ អំពីចំនួនពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ ឬការប្រើប្រាស់អំណាចបំពាន។ យោងតាមតារាងនីតិរដ្ឋអាស៊ានបានចង្អុលថា ទិន្នន័យពាក់ព័ន្ធនឹងបញ្ហានេះ ពុំអាចរកបានទេក្នុងប្រទេសមួយចំនួននៅអាស៊ាន។

៦. តាមការពិនិត្យទៅលើគម្លាតរវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង ការសិក្សាស្រាវជ្រាវរបស់យើងបានបង្ហាញពីលទ្ធភាពដែលអាចធ្វើការវាយតម្លៃបលើប្រសិទ្ធភាពនៃទ្រឹស្តីបែងចែកអំណាច និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលចំពោះមុខច្បាប់ ថាពិតជាមានការអនុវត្តន៍នៅក្នុងប្រទេសជាសមាជិកអាស៊ាន។

៧. នៅប្រទេសវៀតណាម និង ឡាវ កំណែទម្រង់ច្បាប់ជាច្រើនហាក់ដូចជាមានប្រសិទ្ធភាពខ្ពស់នៅក្នុងការអនុវត្តន៍។ បន្ទាប់ពីច្បាប់ត្រូវបានអនុម័ត អនុក្រឹត្យ និងបទបញ្ញានានាត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែម និងធ្វើឲ្យច្បាប់អាចយកទៅអនុវត្តបាន។ ជាងនេះទៀត ការអនុវត្តន៍ច្បាប់ដោយស្ថាប័ននីមួយៗអាចមានភាពប្រទាំងប្រទិស "ដែលធ្វើឲ្យមានភាពខ្វះចន្លោះ មានភាពអសកម្ម មានការបកស្រាយផ្សេងៗ មានភាពលំអៀង និងអំពើពុករលួយ"។[xlix] ជាសង្ខេប ការកំណត់ពីលក្ខណៈច្បាប់ គឺកើតចេញពីបក្សកាន់អំណាច ដោយមិនអាចកំណត់ដាច់ចេញពីច្បាប់ជាតិទេ។ កង្វះការកំណត់ឲ្យបានជាក់លាក់នៃ "ច្បាប់" គឺទុកឱកាសដល់បក្សកាន់អំណាចដាក់បញ្ចូលបន្ថែមនូវបទបញ្ញារបស់ខ្លួន តួយ៉ាង នៅប្រទេសវៀតណាម គឺ "លំបាកក្នុងការកំណត់ ឬផ្តាច់ចេញរវាងរដ្ឋ និងបក្ស ៖ 'បក្សគ្រប់គ្រងរដ្ឋ'។[l]

៨. នៅក្នុងចរន្តដូចគ្នានេះ និយមន័យដែលនាំមានភាពប្រទាំងប្រទើសជុំវិញវគ្គស័ព្ទ ដូចជា "ផ្អែកទៅតាមច្បាប់" "សន្តិសុខផ្ទៃក្នុង" និង "ផលប្រយោជន៍សាធារណៈ" ដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សំខាន់ៗក្នុងប្រទេសអាស៊ាន គឺបានកម្រិតពីសិទ្ធិ និងសេរីភាពជាមូលដ្ឋាន និងផ្តល់អំណាចកាន់តែទូលាយដល់ស្ថាប័ននីតិប្រតិបត្តិ។

៩. រដ្ឋធម្មនុញ្ញក៏បានកំណត់ពីស្ថានភាពវិសាមញ្ញ ដែលអាចឲ្យមានការត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល ក្នុងករណីប្រធើយកន្តើយមិនអនុវត្តតួនាទីរបស់ខ្លួន។ ឧទាហរណ៍ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសសិង្ហបុរី និង ម៉ាឡេស៊ី បានចែងថា សេរីភាពជាមូលដ្ឋានមួយភាគធំអាចត្រូវបានដកហូត ឬរឹតត្បិតក្នុងករណីប្រទេសជួបភាពអាសន្ន។ រដ្ឋធម្មនុញ្ញនៃប្រទេសទាំងពីរ បានបង្កលក្ខណៈតិចតួចដល់ការត្រួតពិនិត្យលើអំណាចប្រតិបត្តិ ចំពោះករណីប្រទេសជួបភាពអាសន្ន។ នៅប្រទេសសិង្ហបុរី ប្រធានាធិបតីអាច

ប្រកាសអាសន្នបានតែក្នុងលក្ខខណ្ឌដែលចែងមានក្នុងរដ្ឋធម្មនុញ្ញ និងពុំមានការត្រួតពិនិត្យពីស្ថាប័នយុត្តិធម៌ក្នុងការប្រើអំណាចផ្តាច់ការនោះទេ។ នៅក្នុងកំឡុងពេលប្រទេសជួបភាពអាសន្ន រដ្ឋសភាអាចអនុម័តច្បាប់ដែលមិនស្របនឹងរដ្ឋធម្មនុញ្ញបាន គឺឲ្យតែរដ្ឋសភាយល់ឃើញថា ច្បាប់នោះអាចជួយសម្រួលដល់ស្ថានភាពអាសន្ននោះ។ នៅប្រទេសប្រ៊ុយណេ (រហូតមកដល់បច្ចុប្បន្ននៅតែស្ថិតក្នុងស្ថានភាពអាសន្ន) បានផ្តល់អំណាចផ្តាច់មុខដល់ស្តេច **ស៊ុលតង់** ដោយពុំកម្រិតសិទ្ធិក្នុងការចេញសេចក្តីសម្រេចនានា គឺឲ្យតែព្រះអង្គយល់ឃើញថា បទបញ្ញានោះការពារដល់ "ផលប្រយោជន៍សាធារណៈ"។

១០. ករណីកម្រិតព្រំដែននៃការប្រើប្រាស់អំណាចរបស់អង្គការនីតិប្រតិបត្តិ ប្រទេសមួយចំនួននៅអាស៊ានបានបង្កើតស្ថាប័នដើម្បីត្រួតពិនិត្យលើករណីនេះ។ ឧទាហរណ៍ នៅប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន និង ថៃ បានបង្កើតស្ថាប័ន ដូចជា ការិយាល័យរដ្ឋាភិបាល គណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិ និងតុលាការធម្មនុញ្ញ ដើរតួជាតុលាការ ឬជាអ្នកឃ្លាំមើលលើបញ្ហានេះ។

១១. ក្នុងឆ្នាំ១៩៩៧ ប្រទេសថៃបានបង្កើតនូវយន្តការ ដែលមានឈ្មោះថា "តុលាការធម្មនុញ្ញ" "តុលាការរដ្ឋបាល" "គណៈកម្មការជាតិការពារសិទ្ធិមនុស្ស" "ការិយាល័យរដ្ឋាភិបាលទទួលពាក្យបណ្តឹង" "នាយកដ្ឋានព្រហ្មទណ្ឌនៃតុលាការកំពូលទទួលបណ្តឹងផ្នែកនយោបាយ" និង "គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ"។ នៅប្រទេសឥណ្ឌូនេស៊ី យន្តការត្រួតពិនិត្យនេះ បានលេចចេញជារូបរាង ដើម្បីតាមដានឃ្លាំមើលការអនុវត្តន៍របស់ចៅក្រមតុលាការកំពូល ក្រឡាបញ្ជី រដ្ឋអាជ្ញា ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងនគរបាលជាតិ។ នៅប្រទេសហ្វីលីពីន ការិយាល័យរដ្ឋាភិបាល គណៈកម្មការផ្តល់សេវាដោយមន្ត្រីរដ្ឋការស៊ីវិល ប្រធានស្ថាប័ន ខុទ្ទកាល័យប្រធានាធិបតី ក្រុមប្រឹក្សាច្បាប់នៃរដ្ឋបាលមូលដ្ឋាន និងតុលាការនានាអាចចាត់វិធានការដាក់វិន័យរដ្ឋបាលប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាលដែលប្រព្រឹត្តល្មើស។ ទោះបីជាយ៉ាងណា ការទទួលបានសេវាពីស្ថាប័នទាំងនេះ និងការអនុវត្តន៍ច្បាប់នានា គឺមានដំណើរការខុសគ្នាៗទៅតាមប្រទេសនីមួយៗ។

១២. នៅប្រទេសថៃ បន្ថែមលើទណ្ឌកម្មព្រហ្មទណ្ឌ មន្ត្រី និងភ្នាក់ងាររដ្ឋាភិបាល ក៏ត្រូវប្រឈមនឹងការទទួលខុសត្រូវលើបណ្តឹងរដ្ឋប្បវេណី ចំពោះការប្រព្រឹត្តកំហុសវិន័យ។ ផ្ទុយទៅវិញ នៅប្រទេសឥណ្ឌូនេស៊ីការស៊ើបអង្កេតអំពីកំហុសរបស់មន្ត្រីជាន់ខ្ពស់ដោយរដ្ឋអាជ្ញាសាធារណៈ និងស្ថាប័នមានសមត្ថកិច្ចនានា គឺមិនអាចដំណើរការដោយគ្មានការអនុញ្ញាតពីប្រធានាធិបតី ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអភិបាលខេត្ត (អាស្រ័យទៅតាមបញ្ហាដែលបានកើតឡើង)។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ការទាមទារឲ្យមានបទបញ្ញាបែបនេះ អាចការពារទប់ស្កាត់ការជ្រៀតជ្រែតពីសំណាក់រដ្ឋាភិបាលនៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

១៣. ជាការពិតណាស់ ស្ថាប័នឃ្លាំមើល ដូចជា ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ អាចផ្លាស់ប្តូរប្រសិទ្ធភាព ឬដែនកំណត់របស់ខ្លួន គឺអាស្រ័យទៅតាមអណត្តិ និងការផ្តល់អំណាច។ ឧទាហរណ៍ គណៈកម្មការសិទ្ធិមនុស្សប្រចាំនៅប្រទេសម៉ាឡេស៊ី មានដែនកម្រិតអំពីអំណាច និងឥទ្ធិពលនៅក្នុងការអនុវត្តន៍ជាក់ស្តែង។ នៅប្រទេសហ្វីលីពីន ការិយាល័យទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ គឺគ្រប់គ្រងដោយមន្ត្រីសាធារណៈទាំងក្នុងចំណាត់ការ និងសកម្មភាព។ នៅពេលមានការ "ប្រព្រឹត្តកំហុស ឬដំណើរការមិនយុត្តិធម៌ ឬមានភាព

មិនប្រក្រតី ឬមិនមានប្រសិទ្ធភាព″ ការដកហូតតំណែងតួនាទីរបស់មន្ត្រីទាំងនោះ អាចធ្វើឡើងដោយសមាជិកសភា និងចៅក្រម។ ទោះបីជាមានបណ្តឹងជាច្រើនត្រូវបានស្ថាប័នទទួលពាក្យបណ្តឹងធ្វើការដោះស្រាយ ក៏មានមតិភាគច្រើនលើកឡើងថា ដំណើរការវិនិច្ឆ័យមិនមានប្រសិទ្ធភាព ដូចជា ករណីមនុស្សឃាតដែលបណ្តាលមកពីមូលហេតុនយោបាយ និងការបាត់ខ្លួនដោយបង្ខំ ដែលនេះបង្ហាញពីកង្វះការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋាភិបាល។

១៤. ជាការសន្និដ្ឋានរួម បណ្តាប្រទេសជាសមាជិកអាស៊ាន បានកំណត់ពីការបែងចែកអំណាច និងការទទួលខុសត្រូវចំពោះមុខច្បាប់ ប៉ុន្តែ ប្បញ្ញត្តិនេះពុំត្រូវបានអនុវត្តឲ្យមានប្រសិទ្ធភាព។ ការបង្កើតឲ្យមានស្ថាប័នត្រួតពិនិត្យ ពុំបានធានាថា សិទ្ធិជាមូលដ្ឋានត្រូវបានការពារឡើយ។ ការសិក្សាស្រាវជ្រាវបន្ថែម តម្រូវឲ្យមានការប្រមូលរកនូវទិន្នន័យ ដែលជាឧបសគ្គនាំឲ្យមន្ត្រីរដ្ឋាភិបាលមិនត្រូវបានយកមកទទួលខុសត្រូវចំពោះមុខច្បាប់ និងការកសាងសមត្ថភាព ព្រមទាំងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធច្បាប់។

<u>ឃ- គោលការណ៍ស្នូលទី២ ៖ ច្បាប់ និងនីតិវិធីក្នុងការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ទណ្ឌកម្មអាចស្វែងរកបានជាសាធារណៈ ដោយស្របច្បាប់ និងមិនលំអៀង</u>

១. ដូចបានកំណត់នៅក្នុងតារាងនីតិរដ្ឋអាស៊ាន ប្រទេសជាសមាជិកអាស៊ានស្ទើរតែទាំងអស់បានកំណត់ចែងក្នុងច្បាប់របស់ខ្លួន អំពីមូលហេតុ និងនីតិវិធីក្នុងការចាប់ខ្លួន ដំណើរការកាត់ទោស និងការឃុំខ្លួន។ តាមរយៈទ្រឹស្តីសិទ្ធិមនុស្ស ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ពីការអនុវត្តន៍ច្បាប់ដោយយុត្តិធម៌ និងស្មើភាព។ ឧទាហរណ៍ ក្រមនីតិវិធីព្រហ្មទណ្ឌនៅប្រទេសវៀតណាម បានកំណត់ថា ជនជាប់ឃុំឃាំង និងជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬដោយស្មាក្តី និងទទួលបានការជំនុំជម្រះជាសាធារណៈដោយមានសិទ្ធិផ្តល់ភស្តុតាង និងផ្តល់ព័ត៌មានពិតជូនតុលាការ។ បទប្បញ្ញត្តិនេះ ក៏មានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសឥណ្ឌូនេស៊ី ថៃ និង ហ្វីលីពីន ហើយហាមឃាត់ដាច់ខាត់ការឃុំខ្លួនដោយពុំមានការជំនុំជម្រះ ការឃុំខ្លួនហួសនីតិវិធី ដំណើរការក្តីដោយមិនយុត្តិធម៌ និងការសន្មតថាមានទោស។

២. ភាពខុសប្លែកគ្នានៅអាស៊ាន គឺការចូលជាសមាជិកនៃអនុសញ្ញាសិទ្ធិមនុស្ស។

៣. ប្រទេសមួយចំនួន ដូចជា ប្រទេសសឹង្ហបុរី ម៉ាឡេស៊ី ប្រ៊ុយណេ និង ភូមា ពុំបានផ្តល់សច្ចាប័ន ឬទទួលយកលិខិតុបករណ៍ច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សសំខាន់ៗជាច្រើន។ ផ្ទុយទៅវិញ ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នស្ទើរគ្រប់លិខិតុបករណ៍ទាំងអស់។ ប្រទេសកម្ពុជា គឺជារដ្ឋតែមួយគត់នៅអាស៊ានដែលផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីការប្រឆាំងនឹងអំពើធ្វើទារុណកម្ម និងសន្ធិសញ្ញាទីក្រុងរ៉ូម ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា (អ.វ.ត.ក) ដែលជាតុលាការកូនកាត់ ក្រោមជំនួយគាំទ្រពីអង្គការសហប្រជាជាតិ នាពេលបច្ចុប្បន្ន បាននឹងកំពុងកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមពីបទឧក្រិដ្ឋកម្មអន្តរជាតិ ដែលនេះជាគំរូដ៏ល្អមួយសម្រាប់តុលាការក្នុងស្រុក។ បន្ទាប់ពីការសិក្សាលម្អិតអំពីយុត្តាធិការ និងការផ្តួចផ្តើមបង្កើត អ.វ.ត.ក របាយការណ៍ប្រចាំប្រទេសនេះ បានលើក

ឡើងថា អ.វ.ត.ក នឹងផ្តល់កេរដំណែលជានិរន្តន៍ចំពោះនីតិរដ្ឋនៅកម្ពុជា និងជួយពង្រឹងស្ថាប័នយុត្តិធម៌ក្នុងស្រុក និងការកសាងសមត្ថភាពអ្នកច្បាប់។

៤. ទោះបីជាយ៉ាងណាក៏នៅតែមានឧបសគ្គ និងដែនកំណត់ចំពោះការអនុវត្តន៍ច្បាប់នៅប្រទេសកម្ពុជា ក៏ដូចជាប្រទេសនានានៅអាស៊ាន។ បញ្ហានេះបានឆ្លុះបញ្ចាំងឲ្យឃើញពីផលប៉ះពាល់មិនល្អ ចំពោះការគោរពសិទ្ធិសេរីភាព ៖ ទី១- ច្បាប់មួយចំនួនពិតជាមានភាពលំអៀង ដោយសារការមិនបានធានាពីការការពារសិទ្ធិមនុស្ស ដូចជា ច្បាប់សន្តិសុខផ្ទៃក្នុងនៅប្រទេសសឹង្ហបុរី ម៉ាឡេស៊ី និងប្រ៊ុយណេ បានអនុញ្ញាតឲ្យមានការឃុំខ្លួន ការចោទប្រកាន់ និងការជំនុំជម្រះក្តីដោយគ្មានមូលហេតុត្រឹមត្រូវ (ដូចបានរៀបរាប់ខាងលើ)។ ជាក់ស្តែង ដំណែលដែលបានបន្សល់ទុកពីនឹមបអាណានិគម ដូចជា ច្បាប់សន្តិសុខផ្ទៃក្នុង និងច្បាប់ប្រកាសភាពអាសន្ននៅក្នុងបណ្តាប្រទេសទាំងនេះ ពិតជាមានលក្ខណៈស្រដៀងគ្នា បើពិនិត្យមើលទៅលើទម្រង់។ ទោះបីជា ច្បាប់ទប់ស្កាត់ការឃុំខ្លួនដោយសេរី ត្រូវបានត្រួតពិនិត្យជារៀងរាល់ពីរឆ្នាំម្តង ក៏នៅតែមានមតិលើកឡើងថា រយៈពេលនៃការឃុំខ្លួនគួរត្រូវបានពិនិត្យឡើងវិញដោយស្ថាប័នមានសមត្ថកិច្ច។ ការពុំទទួលបានការវាយតម្លៃពីស្ថាប័នយុត្តិធម៌ គឺហាក់ដូចជាកម្រិតសិទ្ធិរបស់ជនជាប់ឃុំឃាំងក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

៥. ភាពខុសប្លែកគ្នានៃបទប្បញ្ញត្តិ និងច្បាប់នានា បានបង្ហាញពីលំដាប់នៃការចងក្រងច្បាប់នៅអាស៊ាន ថាពិតជាបានផ្តល់អំណាចដោយបំពានក្នុងការដកហូតសេរីភាព និងសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ។ ឧទាហរណ៍ នៅប្រទេសប្រ៊ុយណេ ច្បាប់បានហាមឃាត់ "ការបំពានសិទ្ធិបុគ្គល" ប្រឆាំងនឹងជនជាប់ឃុំឃាំង ប៉ុន្តែមានករណីលើកលែង "នៅពេលមានការមិនរៀងចាល និងមិនគោរពបទបញ្ជា"។ នៅប្រទេសឥណ្ឌូនេស៊ី ទោះបីជាច្បាប់បានកំណត់ពីដំណើរការនីតិវិធីដោយស្របច្បាប់ ក៏ក្រមនីតិវិធីព្រហ្មទណ្ឌនៅតែអនុញ្ញាតឲ្យមានការពន្យារពេលការឃុំខ្លួននៅក្នុងដំណាក់កាលស៊ើបសួរបឋម ដែលនេះរឹតត្បិតដល់សិទ្ធិទទួលការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ពង្រាងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនៃប្រទេសនេះបានចែងកំណត់យ៉ាងជាក់លាក់ពីបញ្ហានេះ ក៏ប៉ុន្តែច្បាប់នេះនៅមិនទាន់អនុវត្តនៅឡើយ។

៦. បញ្ហាក្នុងការអនុវត្តន៍ច្បាប់ដោយលំអៀង អាចកើតមាននៅពេលដែលច្បាប់ពុំបានចែងច្បាស់។ គោលការណ៍ច្បាស់លាស់ និងភាពសន្មតទុកជាមុននៃច្បាប់ គឺជាផ្នែកមួយនៃការកំណត់នីតិរដ្ឋ។ គោល-ការណ៍ទាំងនេះតម្រូវឲ្យច្បាប់ត្រូវតែតាក់តែងឡើងឲ្យមានភាពពិតប្រាកដ និងច្បាស់លាស់ ដូច្នេះប្រជាពលរដ្ឋអាចអនុវត្តដោយត្រឹមត្រូវដោយផ្អែកលើបទដ្ឋាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រមព្រហ្មទណ្ឌនៃប្រទេសវៀតណាម បានហាមឃាត់ការប្រឆាំងនឹង "ការធ្វើឲ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធរបស់សង្គមនិយម" និង "កំណត់គុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យ ថាជាការរំលោភបំពានទៅលើផលប្រយោជន៍រដ្ឋ និងសង្គម" ដែលចំណុចនេះ ត្រូវបានរិះគន់យ៉ាងខ្លាំងថាជាការអនុវត្តច្បាប់ដោយលំអៀង។

៧. ស្រដៀងគ្នានេះ មានការរិះគន់ជាច្រើនចំពោះការអនុវត្តន៍ច្បាប់នានា នៅប្រទេសភូមា ឡាវ និងកម្ពុជា។ ដំណើរការអនុវត្តន៍ ឬបន្តអនុវត្តច្បាប់មជ្ឈត្តករ គឺហាក់ដូចជាពុំបានបង្ហាញពីការគោរពដំណើរការនីតិវិធីដោយស្របច្បាប់ និងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ហើយពុំនាំឆ្ពោះទៅរកនីតិរដ្ឋ ដែលតម្រូវឲ្យ

មានភាពច្បាស់លាស់ និងប្រាកដប្រជាក្នុងការរៀបចំ និងបង្កើតច្បាប់។ ដូចគ្នានេះ ច្បាប់សន្តិសុខមនុស្សជាតិនៅប្រទេសហ្វីលីពីន ច្បាប់ប្រឆាំងនឹងភេរវកម្មនៅប្រទេសឥណ្ឌូនេស៊ី ច្បាប់សន្តិសុខផ្ទៃក្នុងនៅប្រទេសថៃ ត្រូវបានរិះគន់ថា ពុំបានសិក្សាឲ្យបានច្បាស់លាស់ មុននឹងដាក់ឲ្យប្រើប្រាស់ ដែលជាហេតុនាំឲ្យមានការបំពានទៅលើដំណើរការនីតិវិធីស្របច្បាប់ និងសមភាព។

៨. ទី២ ៖ ច្បាប់ត្រូវតាក់តែងឲ្យបានច្បាស់លាស់ និងប្រាកដប្រជា បើមិនដូច្នោះនឹងឆ្លុះបញ្ចាំងពីលក្ខណៈលំអៀងនៅពេលយកទៅអនុវត្ត។ ជាការពិត ភាពលំអៀងក្នុងការអនុវត្តន៍ច្បាប់ គឺអាចកើតមាននៅគ្រប់ប្រព័ន្ធច្បាប់ ទាំងក្នុងតំបន់ និងគ្រប់ទិសទី។ ក្តីបារម្ភនៃនីតិរដ្ឋ គឺនៅពេលដែលការអនុវត្តន៍ច្បាប់នានាមានលក្ខណៈលំអៀង ដូចជា ការដកហូតសិទ្ធិបុគ្គល ឬក្រុមមនុស្ស ដែលមានការធានាដោយរដ្ឋធម្មនុញ្ញ។ ឧទាហរណ៍ ច្បាប់បានប្បញ្ញត្តិពីសិទ្ធិការពារខ្លួនស្របច្បាប់ប្រឆាំងទៅនឹងការចោទប្រកាន់ព្រហ្មទណ្ឌ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែងនៅមានកម្រិត គឺថា មេធាវីនៅតែមិនអាចការពារកូនក្តីខ្លួនដោយសមស្រប។

៩. ករណីនេះកើតឡើងជាញឹកញាប់ ទោះបីជាច្បាប់ក្នុងប្រទេសអាស៊ានបានផ្តល់ការធានាយ៉ាងត្រឹមត្រូវ ប៉ុន្តែការអនុវត្តន៍ជារឿងមួយដោយឡែក។ យោងតាមអ្នកសង្កេតការណ៍ប្រចាំប្រទេសវៀតណាម ឥណ្ឌូនេស៊ី កម្ពុជា និងរដ្ឋជាសមាជិកអាស៊ានដទៃទៀត បានលើកឡើងពីការអនុវត្តន៍ច្បាប់ខុសៗគ្នា។[li]

១០. កង្វះការអនុវត្តន៍ច្បាប់ឲ្យបានត្រឹមត្រូវ ធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ជនជាប់ចោទ តាមរយៈការសិក្សាស្រាវជ្រាវ បានបង្ហាញពីភាពកម្សោយនៃនីតិរដ្ឋ។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីន រដ្ឋធម្មនុញ្ញបានហាមប្រាមការឃុំខ្លួនហួសនីតិវិធីច្បាប់ ការប្រព្រឹត្តបែបអមនុស្សធម៌ ហើយក្រមព្រហ្មទណ្ឌបានកំណត់ដាក់ទោសចំពោះការប្រព្រឹត្តមិនត្រឹមត្រូវលើអ្នកទោស។[lii] ការចាប់ខ្លួនដោយខុសច្បាប់ ឬការឃុំខ្លួនដោយលំអៀងគឺជាបទល្មើសព្រហ្មទណ្ឌ។[liii] ករណីជាច្រើនដែលដំណើរការតាមប្រព័ន្ធយុត្តិធម៌ ដូចជា ការសម្លាប់ដោយការសងសឹក ការបង្ខំឲ្យបាត់ខ្លួន ការធ្វើទារុណកម្ម ការចាប់ខ្លួនដោយខុសច្បាប់ ព្រមទាំងការឆែកឆេរ និងការរឹបអូសខុសច្បាប់។[liv] ប្រធានាធិបតី **អារ្វយ៉ូ** បានផ្តួចផ្តើមឲ្យមានការស៊ើបអង្កេតលើការសម្លាប់មនុស្សដោយរង្គាល ដែលនេះបង្ហាញពីការទទួលខុសត្រូវស្គាល់របស់រដ្ឋាភិបាល។[lv] ចំពោះការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ គួរកំណត់ពីមូលហេតុដែលផ្តួចផ្តើមនាំឲ្យមានប្រឆាំង ឬការរំលោភសិទ្ធិមនុស្ស និងប្រៀបធៀបមេរៀនដកពិសោធន៍នៅប្រទេសហ្វីលីពីនជាមួយបណ្តាប្រទេសនានានៅអាស៊ាន។

១១. កង្វះការព្យាករណ៍នៃច្បាប់ គឺកំពុងស្ថិតជាកង្វល់នៅអាស៊ាន ដូចបានលើកឡើងខាងលើ ការព្យាករណ៍ និងភាពប្រាកដប្រជា គឺជាធាតុស្នូលនៃនីតិរដ្ឋ។ នៅក្នុងការសិក្សាស្រាវជ្រាវប្រចាំប្រទេសហ្វីលីពីន ទិន្នន័យ ៤៣% បានបង្ហាញថា ចៅក្រមបានចេញសេចក្តីសម្រេចដោយមានការព្យាករណ៍ទុកជាមុន និងតិចជាង ១៥% បានបង្ហាញថា មេធាវីទទួលស្គាល់ពីសេចក្តីសម្រេចរបស់តុលាការដោយមានការព្យាករណ៍ទុកជាមុន។[lvi]

១២. ជាការសន្និដ្ឋាន ការសិក្សាស្រាវជ្រាវជាមូលដ្ឋានរបស់យើង បានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសជាសមាជិកអាស៊ានភាគច្រើនបានអនុម័តបទប្បញ្ញត្តិ ឬមានរដ្ឋធម្មនុញ្ញ ដែលផ្តល់ក្របខណ្ឌច្បាប់ក្នុងការ

ធានានូវសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទាក់ទងនឹងការចាប់ខ្លួន ការកាត់ទោស និងការឃុំខ្លួន។ ទោះបីជាយ៉ាងណា ការសិក្សាស្រាវជ្រាវនេះ ក៏បានបង្ហាញថា ប្រទេសជាសមាជិកអាស៊ានមួយចំនួនបានបង្កើតច្បាប់ដែលពុំសមស្រប ឬមានប្រការលើកលែងសំខាន់ៗ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិមនុស្ស។ ការលើកឡើងថា ទោះបីជាមានវត្តមានក្របខណ្ឌនីតិរដ្ឋ ក៏សិទ្ធិទទួលបានដំណើរការនីតិវិធីដោយស្របច្បាប់នៅតែជួបឧបសគ្គ ដោយសារតែការអនុវត្តន៍លំអៀង ដែលបង្ហាញថា "នីតិរដ្ឋ គឺមានតែឈ្មោះ" (តាមរយៈ ការស្រាវជ្រាវជាក់ស្តែងក្នុងប្រទេសជាសមាជិកអាស៊ាន)។

១៣. តាមរយៈការសិក្សាស្រាវជ្រាវជាមូលដ្ឋានរបស់យើង គឺទាមទារឲ្យមានការស្រាវជ្រាវបន្ថែមចំពោះច្បាប់ និងបទប្បញ្ញត្តិក្នុងតំបន់ ដែលអាចជួយលើកកម្ពស់យុទ្ធសាស្ត្រពង្រឹងហេដ្ឋារចនាសម្ព័ន្ធច្បាប់ ផ្តោតសំខាន់សិទ្ធិទទួលបានដំណើរការនីតិវិធីដោយស្របច្បាប់ ការការពារប្រឆាំងមិនឲ្យកើតមានច្បាប់ ដែលពុំមានសុក្រឹតភាពនិងជួយពង្រឹងច្បាប់ឲ្យមានភាពប្រាកដប្រជា និងមានការព្យាករណ៍។

## ង- គោលការណ៍ស្នូលទី៣ ៖ ដំណើរការបង្កើតច្បាប់ និងការចូលជាធរមាន ងាយស្រួលស្វែងយល់ យុត្តិធម៌ មានប្រសិទ្ធភាព និងអនុវត្តដោយស្មើភាព

១. ច្បាប់នៅប្រទេសឥណ្ឌូនេស៊ី ថៃ ម៉ាឡេស៊ី ប្រ៊ុយណេ និង ហ្វីលីពីន គឺអាចស្វែងរកបានដោយងាយស្រួល ទាំងឯកសារបោះពុម្ព និងឌីជីថល។ នៅប្រទេសហ្វីលីពីន ជាចំណុចវិជ្ជមាន គឺថា ច្បាប់នឹងចូលជាធរមាននៅក្នុងរយៈពេល ១៥ថ្ងៃ។[lvii] ដូចគ្នានេះ យោងតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសថៃ ច្បាប់អាចចូលជាធរមាន និងអនុវត្តបានលុះត្រាតែបានផ្សព្វផ្សាយនៅក្នុងព្រះរាជកិច្ច។

២. ក្រៅពីការចូលធរមាននៃច្បាប់ នីតិរដ្ឋក៏កំណត់ថា ដំណើរការនៃការអនុម័តច្បាប់ គួរតែមានភាពច្បាស់លាស់ និងមានតម្លាភាព។ នៅប្រទេសសឹង្ហបុរី និង ម៉ាឡេស៊ី កិច្ចប្រជុំសភាបើកចំហរជាសាធារណៈ កាលបរិច្ឆេទ ពេលវេលាកិច្ចប្រជុំ និងសេចក្តីព្រាងច្បាប់ ត្រូវបានចែកផ្សាយជាសាធារណៈ។ នៅប្រទេសកម្ពុជា ឡាវ និង វៀតណាម ក៏មាននីតិវិធីច្បាស់លាស់ក្នុងការអនុម័តច្បាប់ តាមរយៈរដ្ឋសភា (ឬសភាជាតិ)។ ចំណែកឯ នីតិវិធីធ្វើច្បាប់នៅប្រទេសថៃ និង ហ្វីលីពីន ក៏បើកចំហរជាសាធារណៈ និងបានធានាពីភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន ដូចជា តាមរយៈការផ្សាយបន្តផ្ទាល់តាមប្រព័ន្ធអ៊ិនធឺណែត ដោយជូនភ្ជាប់នូវសេចក្តីព្រាងច្បាប់ ព្រមជាមួយកំណត់សេចក្តី ប្រតិចារិក កំណត់ហេតុ សេចក្តីសម្រេច និងដំណោះស្រាយនានា។ នៅប្រទេសហ្វីលីពីន សិទ្ធិទទួលបានព័ត៌មាន គឺមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។

៣. បទប្បញ្ញត្តិសំខាន់ៗនៅប្រទេសវៀតណាមទាក់ទងនឹងបញ្ហានេះ រួមមាន ច្បាប់ស្តីពីការផ្សព្វផ្សាយឯកសារច្បាប់ ដែលជាទូទៅហៅថា "ច្បាប់អំពីច្បាប់"។ យោងតាមវិសោធនកម្មនៅឆ្នាំ២០០២ និងឆ្នាំ ២០០៨ បានចែងថា កំណែប្រែចុងក្រោយនៃពង្រាងច្បាប់ត្រូវបានតម្រូវឲ្យផ្សព្វផ្សាយជាសាធារណៈ ក្នុងរយៈពេល ៦០ថ្ងៃ ដើម្បីទទួលមតិយោបល់ពីសាធារណជន។ ប្រទេសវៀតណាម បានទទួលយកមតិយោបល់សាធារណជនដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងច្បាប់សំខាន់ៗជាច្រើន បើទោះជាមានការចូលរួមដ៏តិចតួចពីសាធារណជន។

៤. ផ្ទុយទៅវិញ នៅប្រទេសប្រ៊ុយណេដំណើរការធ្វើច្បាប់មិនត្រូវបានបើកចំហរជាសាធារណៈទេ។ ចំណែកនៅប្រទេសឥណ្ឌូនេស៊ីក៏ដូច្នេះដែរ សិទ្ធិចូលរួមក្នុងដំណើរការធ្វើច្បាប់ គឺមានកម្រិត ដែលជាហេតុធ្វើឲ្យសាធារណជនលំបាកក្នុងការតាមដានដំណើរការរៀបចំច្បាប់។ ការវិវត្តន៍នៃកំណែទម្រង់សភានៅប្រទេសភូមា ពាក់ព័ន្ធនឹងការបង្កើតច្បាប់ថ្មីៗកំពុងស្ថិតក្នុងការឃ្លាំមើល ថាតើដំណើរការនោះបានវិវត្តន៍ត្រឹមកម្រិតណា ចាប់តាំងពីការគ្រប់គ្រងដោយអំណាចយោធា។

៥. នៅក្នុងប្រព័ន្ធច្បាប់សិទ្ធិចូលរួមយោបល់ក្នុងដំណើរការធ្វើច្បាប់ ពិតជាមានសារសំខាន់សម្រាប់សាធារណជនទូទៅ ជាពិសេស សម្រាប់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ សមភាពចំពោះមុខច្បាប់ និងសិទ្ធិចូលរួមក្នុងដំណើរការច្បាប់គឺជាធាតុដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំងអំពីនីតិរដ្ឋ។ នីតិរដ្ឋតម្រូវឲ្យសាធារណជនមានសិទ្ធិស្មើគ្នាក្នុងការទទួលបានយុត្តិធម៌ និងសេវាសង្គមនានា។[lviii] ប្រទេសនីមួយៗនៅអាស៊ាន បានអនុម័តយន្តការផ្សេងៗគ្នាក្នុងការដោះស្រាយបញ្ហានេះ។

៦. នៅប្រទេសសិង្ហបុរី មានការផ្ដួចផ្ដើមជាច្រើន ដើម្បីជួយដល់ដើមបណ្ដឹងឲ្យទទួលបានយុត្តិធម៌។ ឧទាហរណ៍ មានក្របខណ្ឌជំនួយផ្នែកច្បាប់សម្រាប់រឿងក្ដីរដ្ឋប្បវេណី និងរឿងក្ដីព្រហ្មទណ្ឌ ហើយស្ថាប័ននានា ដូចជា មជ្ឈមណ្ឌលសម្របសម្រួលសហគមន៍ និងតុលាការមូលដ្ឋាន ត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការប្រើប្រាស់យន្តការដោះស្រាយជម្លោះ។ នៅប្រទេសប្រ៊ុយណេ ការិយាល័យផ្ដល់ប្រឹក្សាយោបល់ផ្នែកច្បាប់ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ សម្រាប់ជួយដល់ប្រជាជនដែលមានប្រាក់ចំណូលទាប ប៉ុន្តែ នៅប្រទេសម៉ាឡេស៊ី ប្រព័ន្ធជំនួយផ្នែកច្បាប់ហាក់ដូចជាមិនមានដំណើរការវិវត្តន៍ទេ។ ទោះបីជាមានជំនួយផ្នែកច្បាប់សម្រាប់ដំណើរការកាត់ក្ដីព្រហ្មទណ្ឌ និងបញ្ហាស៊ីវិល ក៏ដើមបណ្ដឹងភាគច្រើននៅតែពឹងផ្អែកលើការិយាល័យជំនួយផ្នែកច្បាប់ស្ម័គ្រចិត្ត ដែលពុំអាចរ៉ាប់រងគ្រប់តម្រូវការរបស់ប្រជាជនទាំងមូលនោះទេ។

៧. ជំនួយផ្នែកច្បាប់ក៏មាននៅប្រទេសកម្ពុជា ប៉ុន្តែស្ថិតក្រោមការផ្ដួចផ្ដើមរបស់អង្គការសង្គមស៊ីវិល ដូចជា គម្រោងអ្នកការពារច្បាប់កម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ចំណែកឯនៅប្រទេសវៀតណាម យន្តការនេះ គឺស្ថិតក្រោមការឧបត្ថម្ភពីរដ្ឋាភិបាល ចំណែកឯនៅប្រទេសភូមាពុំមានយន្តការនេះទេ។ ជំនួយផ្នែកច្បាប់ក៏បានផ្ដល់ជូនដល់ប្រជាពលរដ្ឋដែលពុំមានលទ្ធភាពនៅប្រទេសថៃ និងហ្វីលីពីន ដើម្បីធានាការការពារសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងសិទ្ធិទទួលបានយុត្តិធម៌។ ការិយាល័យជំនួយផ្នែកច្បាប់នៅប្រទេសថៃ បានផ្ដល់សេវាដោយឥតគិតថ្លៃ ទាំងការប្រឹក្សាយោបល់ និងមេធាវី។ សេវាជំនួយផ្នែកច្បាប់ក៏អាចស្វែងរកបាននៅគណៈមេធាវីនៃប្រទេសថៃ ឬការិយាល័យអគ្គព្រះរាជអាជ្ញា។ នៅប្រទេសហ្វីលីពីន ការិយាល័យមេធាវីសាធារណៈ គឺផ្ដល់សេវាជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនជាប់ចោទក្រីក្រ ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្ដែង គឺជួបបញ្ហាលំបាកក្នុងការទទួលបានសេវានេះ។ យោងតាមការវាយតម្លៃមួយ គឺថាករណីព្រហ្មទណ្ឌដែលជួយដោះស្រាយដោយនាយកដ្ឋានជនក្រីក្រនៅហ្វីលីពីន ក៏នៅតែចំណាយប្រហែលជាបីដងនៃប្រាក់សន្សំប្រចាំឆ្នាំជាមធ្យមរបស់គ្រួសារនីមួយៗ។ គួរគត់សម្គាល់ ប្រជាជនខ្សត់ខ្សោយ និងក្រីក្រនៅប្រទេសឥណ្ឌូនេស៊ី ពុំទទួលបានសេវាគាំពារត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌។[lix]

៨. បញ្ហាទទួលបានយុត្តិធម៌ និងចំណោទអំពីសមធម៌ចំពោះមុខច្បាប់ក៏កើតមាននៅតំបន់ស្វយ័តដែលមានការគ្រប់គ្រងយុត្តិធម៌ដាច់ដោយឡែក។ ឧទាហរណ៍ ការបញ្ចូលច្បាប់មូស្លីម (ShariaLaw) នៅក្នុងស្ថានភាព និងតំបន់ជាក់លាក់ នៅប្រទេសសឹង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និង ហ្វីលីពីន។ ទោះបីជានៅប្រទេសថៃ ពុំមានតុលាការមូស្លីមដាច់ដោយឡែក (Sharia Court) ក៏នៅក្នុងរឿងក្តីដែលមានភាគីជាជនជាតិមូស្លីម ដូចជា រឿងក្តីគ្រួសារ និងការបែងចែកទ្រព្យសម្បត្តិចៅក្រមជនជាតិមូស្លីម ត្រូវបានចាត់តាំងឲ្យទទួលបន្ទុកឲ្យដោះស្រាយបញ្ហានេះ។ នៅប្រទេសហ្វីលីពីន ក្រមព្រហ្មទណ្ឌមូស្លីមដាច់ដោយឡែក អាចអនុវត្តទៅលើក្រុមជនជាតិមស្លីម។ ចំណែកឯប្រទេសឥណ្ឌូនេស៊ីនៅតំបន់មួយចំនួនមានប្បញ្ញត្តិដោយឡែកពាក់ព័ន្ធនឹងករណីមូស្លីម (Sharia Inspired) ដូចជា ការរើសអើងប្រឆាំងស្ត្រី។ ការសិក្សាស្រាវជ្រាវបន្ថែមគួរត្រូវធ្វើឡើងដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីច្បាប់សាសនា/ទំនៀមទម្លាប់ និងច្បាប់ពហុព័ន្ធភាព ព្រមទាំងផលប៉ះពាល់ចំពោះគោលការណ៍ស្មើភាពចំពោះមុខច្បាប់។ ការសិក្សាស្រាវជ្រាវបន្ថែម ក៏គួរពិចារណាពីយុត្តាធិការរវាងយុត្តិធម៌តាមប្រព័ន្ធផ្លូវច្បាប់ និងតាមប្រព័ន្ធសាសនា/ទំនៀមទម្លាប់។ ការខិតកៀកទៅរកការអនុវត្តន៍បែបសាសនា/ទំនៀមទម្លាប់ គឺជាការផ្ទុយនឹងបទដ្ឋាន និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលច្បាប់ទាំងនេះ អាចនាំឲ្យមានរឹតត្បិត និងច្រានចោលនូវការប្រើប្រាស់យន្តការយុត្តិធម៌តាមបែបទំនៀមទម្លាប់។ ជាលទ្ធផល នាំឲ្យមានការបែងចែកអំណាចនយោបាយ និងអំណាចសេដ្ឋកិច្ចនៅក្នុងវិស័យយុត្តិធម៌ ព្រមទាំងជួយសម្របសម្រួលការចរចា និងការចែករំលែកព័ត៌មានរវាងប្រព័ន្ធយុត្តិធម៌តាមបែបទំនៀមទម្លាប់ និងច្បាប់។

៩. នាពេលថ្មីៗនេះ បានបង្ហាញឲ្យឃើញថា មានការលំបាកដល់អ្នកសិក្សាស្រាវជ្រាវ និងការវាយតម្លៃលើសិទ្ធិក្នុងការទទួលបានយុត្តិធម៌ និងសមធម៌ចំពោះមុខច្បាប់ ដោយហេតុផលថា ប្រទេសនៅអាស៊ានជាច្រើនពុំបានចងក្រង ឬពុំមានការផ្សព្វផ្សាយទិន្នន័យសំខាន់ៗ។ ប្រទេសនៅអាស៊ានមួយចំនួនទិន្នន័យនេះជាការសម្ងាត់ និងមិនអនុញ្ញាតឲ្យផ្សព្វផ្សាយជាសាធារណៈ។ ការវាយតម្លៃឯករាជ្យ គឺកំពុងជួបឧបសគ្គដោយសារតែសវនាការធ្វើមួយចំនួនឡើងជាអសាធារណៈ ជាពិសេស នៅពេលមានការអះអាងថា ជាបញ្ហាសន្តិសុខជាតិ។ ជាលទ្ធផល នៅក្នុងបរិបទជាច្រើន គឺពុំអាចទទួលបានទិន្នន័យដែលត្រឹមត្រូវ និងមានប្រសិទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ និងវិធីសាស្ត្រដាក់ទណ្ឌកម្មចំពោះការមិនអនុវត្តច្បាប់។

១០. នៅពេលប្រទេសនៅអាស៊ានមានក្របខណ្ឌច្បាប់រដ្ឋធម្មនុញ្ញ ដើម្បីសម្របសម្រួលនូវលំហូរព័ត៌មានដោយសេរី ដោយផ្អែកលើបទប្បញ្ញត្តិ និងច្បាប់ជាតិរបស់ប្រទេសនីមួយៗ។ កិច្ចប្រឹងប្រែងក្នុងការកសាងច្បាប់សហគមន៍អាស៊ាននៅឆ្នាំ២០១៥ គឺជាធនធានដ៏សំខាន់ក្នុងការពង្រឹងស្ថាប័នរដ្ឋ។ ការផ្សព្វផ្សាយ និងប្រមូលទិន្នន័យឲ្យបានត្រឹមត្រូវ អំពីតួលេខបទល្មើស សេវាជំនួយផ្នែកច្បាប់ សេចក្តីសម្រេចរបស់តុលាការ និងស្ថិតិព្រហ្មទណ្ឌ និងការវិវត្តន៍នៃច្បាប់ គួរត្រូវចងក្រង។ ករណីមិនមែនត្រឹមតែពង្រឹងតម្លាភាព ប៉ុន្តែក៏ជួយដល់លទ្ធភាពក្នុងការវាយតម្លៃមួយឲ្យបានត្រឹមត្រូវ និងអាចទទួលបាននូវអនុសាសន៍ល្អៗនឹងគោលនយោបាយការពង្រឹង និងការអនុវត្តន៍នីតិរដ្ឋនៅអាស៊ាន។

១១. ក្នុងការធានានូវការអនុវត្តន៍ដំណើរការក្តីប្រកបដោយយុត្តិធម៌ស្របនឹងនីតិរដ្ឋ និងការជំនុំជម្រះដោយយុត្តិធម៌ ដូចជា ជនរងគ្រោះ ជាពិសេសជនរងគ្រោះដែលជាអនីតិជន និងជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទ គឺតម្រូវឲ្យមានការការពារផ្លូវច្បាប់ និងការគាំពារផ្នែកស្មារតី ទាំងនៅមុនពេល ក្នុងពេល

និងក្រោយពេលនៃការជំនុំជម្រះក្ដី។ ទោះបីជាយ៉ាងណាប្រទេសមួយចំនួនមានចំណាត់ការខុសៗគ្នាចំពោះការការពារជនរងគ្រោះ/សាក្សី និងការផ្ដល់ការគាំទ្រ ហើយជាទូទៅក្នុងការអនុវត្តន៍ជាក់ស្ដែង គឺមានការវិវត្តន៍តិចតួចបំផុត ដែលទាមទារឲ្យមានការសិក្សាស្រាវជ្រាវបន្ថែម។

១២. ទោះបីជា ប្រទេសសឹង្ហបុរី ពុំទាន់មានកម្មវិធីការពារសាក្សីCaផ្លូវការណ៍ក៏ការគាំពារសាក្សី និងជនរងគ្រោះដែលជាអនីតិជនធ្វើឡើងដោយមន្ត្រីសាធារណៈ។ នៅប្រទេសម៉ាឡេស៊ី ការបារម្ភត្រូវបានលើកឡើងថា សុវត្ថិភាពរបស់ជនរងគ្រោះ ឬសាក្សី អាចទទួលការគំរាមគំហែងពីចុងជាប់ចោទ ដោយពុំមានការការពារពីមន្ត្រីនគរបាល។ នៅប្រទេសប្រ៊ុយណេ ទោះបីជាមានគម្រោងការពារសាក្សី ច្បាប់ក៏បានការកំណត់ពីឃុំខ្លួនជនរងគ្រោះដែលរងអំពើរំលោភបំពានផ្លូវភេទ ហើយអាចឈានដល់ការដាក់ទោសទណ្ឌ បើសិនជាមិនគោរពតាមបទបញ្ជានៃការឃុំខ្លួន។ ការបរាជ័យពុំបានធ្វើកំណែទម្រង់កម្មវិធីគាំពារសាក្សី គឺឆ្លុះបញ្ចាំងថាជាកត្តារួមចំណែកនាំឲ្យមាននិទណ្ឌភាពចំពោះការកាប់សម្លាប់នៅប្រទេសហ្វីលីពីន ដូចមាន បញ្ជាក់ក្នុងរបាយការណ៍ថា សាក្សីពុំមានឆន្ទៈក្នុងការផ្ដល់សក្ខីកម្ម ហើយបានរារាំងជាង ៨០% នៃរឿងក្ដី ពុំត្រូវបានកាត់ទោស។ នៅប្រទេសឥណ្ឌូនេស៊ី ភ្នាក់ងារគាំពារសាក្សី គឺនៅមិនទាន់អនុវត្តឲ្យបានទូលំទូលាយនៅឡើយទេ។

១៣. ទាក់ទងនឹងសិទ្ធិទទួលបានយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌នៅអាស៊ាន មានការទទួលស្គាល់ថា ជាក់ស្ដែង គឺមានភាពខុសប្លែកគ្នាចំពោះគោលការណ៍ក្នុងការអនុវត្តន៍ ដែលនេះទាមទារឲ្យមានការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីធ្វើការប្រៀបធៀបការអនុវត្តន៍ល្អៗ និងមេរៀនដកពិសោធន៍នានា ដែលអាចយកជាគំរូនៅអាស៊ាន។ ការសិក្សាស្រាវជ្រាវនេះ ក៏បានកំណត់នូវកក្តាសំខាន់បី ដែលគួរឲ្យបារម្ភ ៖ (ក).ការពុំអនុវត្តន៍ច្បាប់ ក្នុងករណីដែលអ្នកប្រព្រឹត្តបំពានមិនត្រូវយកទៅផ្ដន្ទាទោស (ខ).ការអនុវត្តន៍ច្បាប់ដោយអន្លើក្នុងករណីក្រុមមនុស្សជាក់លាក់ ដូចជា សហគមន៍ជនជាតិដើម ឬជនជាតិភាគតិច ពុំទទួលបានការគាំពារ ឬការអនុវត្តន៍ច្បាប់ និង (គ).ការអនុវត្តន៍ច្បាប់ដោយហួសព្រំដែនកំណត់ក្នុងករណីច្បាប់មួយចំនួនត្រូវបានយកទៅអនុវត្តន៍ហួសហេតុចំពោះការទោសទណ្ឌ និងនៅក្នុងលក្ខខណ្ឌ ដូចជា សន្តិសុខជាតិ និងផលប្រយោជន៍សាធារណៈ។

## <u>ច- គោលការណ៍ស្នូលទី៤៖ យុត្តិធម៌ គឺគ្រប់គ្រងដោយស្ថាប័នយុត្តិធម៌ និងតុលាការ ដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង</u>

១. ការសិក្សាស្រាវជ្រាវរបស់យើងបានបង្ហាញឲ្យឃើញពីទស្សនៈទូទៅ និងឥរិយាបថចំពោះភាពឯករាជ្យរបស់តុលាការ និងភាពមិនលំអៀង ក៏ដូចជាការអភិវឌ្ឍន៍ និងវិជ្ជាជីវៈនៅក្នុងស្ថាប័នតុលាការនៅក្នុងប្រទេសអាស៊ាន។

២. ប្រទេសសឹង្ហបុរី គឺជាប់លំដាប់ជួរមុខ ផ្អែកតាមការសិក្សាជាសកលមួយចំពោះការទប់ស្កាត់អំពើពុករលួយ ប៉ុន្តែប្រទេសអាស៊ានដទៃទៀតពុំមានលំដាប់ថ្នាក់នោះទេ។ ប្រធានតុលាការយុត្តិធម៌ប្រទេសសឹង្ហបុរី គឺជាចៅក្រមជនជាតិអាស៊ីតែម្នាក់គត់ដែលទទួលងារកិត្តិយសពីក្រុមប្រឹក្សាតុលាការអន្តរជាតិ ដែល "ជួយលើកកម្ពស់កិត្យានុភាពរបស់តុលាការនៅប្រទេសក្នុងអាស៊ី"។[lx]

៣. ការយល់ឃើញ និងជំនឿទុកចិត្តពីសាធារណជនចំពោះភាពឯករាជ្យ និងភាពមិនលំអៀងរបស់តុលាការក៏មានភាពខុសៗគ្នាដែរ។ នៅប្រទេសសឹង្ហបុរី ប្រជាជនភាគច្រើនមានជំនឿថា យុត្តិធម៌ត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ និងមិនលំអៀង ប៉ុន្តែនៅប្រទេសឥណ្ឌូនេស៊ីសាធារណជនបានបង្ហាញពីការយល់ឃើញថា តុលាការ និងនគរបាល គឺជាស្ថាប័នពុករលួយជាងគេក្នុងចំណោមស្ថាប័ននានា។

៤. ជាការពិតណាស់ មានការរិះគន់ស្មើរគ្រប់ទិដ្ឋភាព ចំពោះការគ្រប់គ្រងយុត្តិធម៌នៅបណ្តាប្រទេសអាស៊ាន។ សូម្បីតែប្រទេសសឹង្ហបុរី ក៏នៅមានការលើកឡើងថា លទ្ធផលនៃការប្រឆាំងនឹងតុលាការ និងការចោទប្រកាន់បង្ខូចនយោបាយក្នុងប្រទេស គឺអាចនាំឲ្យមានការវិនិច្ឆ័យលំអៀង។[lxi]

៥. នៅប្រទេសអាស៊ានដទៃទៀត ការកំណត់ និងចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលពាក់ព័ន្ធនឹងដំណើរការជ្រើសតាំង និងអាណត្តិរបស់ចៅក្រម គឺអាចបង្កជាឧបសគ្គដល់តុលាការ ឬស្ថាប័នពាក់កណ្តាលតុលាការ។ ឧទាហរណ៍ នៅប្រទេសម៉ាឡេស៊ីអគ្គព្រះរាជអាជ្ញា ត្រូវបានតែងតាំងដោយការសព្វព្រះរាជហឫទ័យពីព្រះមហាក្សត្រ ហើយសេចក្តីសម្រេចរបស់ស្តេច គឺទទួលបានយោបល់ពីនាយករដ្ឋមន្ត្រី ដែលនេះជាហានិភ័យមួយ បានបង្ហាញថា អំណាចនីតិប្រតិបត្តិមានឥទ្ធិពលខ្លាំងដល់អគ្គព្រះរាជអាជ្ញាចំពោះការប្រើប្រាស់នូវឆន្ទានុសិទ្ធិខ្លួន។

៦. ស្រដៀងគ្នានេះ ការបង្កើតសាលាក្តីនៅចុងឆ្នាំ១៩៨០ ដើម្បីជំនុំជម្រះករណីរបស់លោកប្រធានាធិបតីម៉ាឡេស៊ី Tun Salleh Abas និងចៅក្រម ដែលបានរិះគន់រដ្ឋាភិបាល ត្រូវបានរិះគៀនជាខ្លាំង គឺថាជាការជ្រៀតជ្រែករបស់អំណាចនីតិប្រតិបត្តិនៅក្នុងការងារតុលាការ និងអំណាចក្នុងការចាត់តាំងចៅក្រម។ នៅប្រទេសប្រ៊ុយណេស្តេច **ស៊ុលតង់** គឺមានអំណាចផ្តាច់មុខក្នុងការតែងតាំងចៅក្រម ប៉ុន្តែពុំមានព័ត៌មានដែលបញ្ជាក់ពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងការតែងតាំង ឬដកហូតតំណែង រហូតមកដល់បច្ចុប្បន្ន ពុំទាន់មានការចោទប្រកាន់ធំៗ អំពីការប្រើឥទ្ធិពលមិនត្រឹមត្រូវនៅក្នុងការងារតុលាការ។

៧. ការរៀបចំឲ្យបានច្បាស់លាស់ពីសុវត្ថិភាពការងារ និងការជួយឧបថម្ភផ្នែកហិរញ្ញវត្ថុ គឺជាផ្នែកមួយធានាដល់មន្ត្រីតុលាការឲ្យអនុវត្តការងារដោយពុំមានភាពភ័យខ្លាច ឬចំណុះបុគ្គលណាម្នាក់។ ដូចដែលបានបង្ហាញក្នុងតារាងនីតិរដ្ឋអាស៊ាន (មើលឧបសម្ព័ន្ធទី២) ក្រៅពីប្រទេសភូមា វៀតណាម និងឡាវ ប្រទេសផ្សេងទៀតបានផ្តល់នូវកិច្ចធានាសន្តិសុខដល់កិច្ចការតុលាការ។ ប្រាក់បៀរវត្សន៍របស់មន្ត្រីតុលាការ គឺមានភាពខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយនៅអាស៊ាន។ ចៅក្រមនៅប្រទេសសឹង្ហបុរីទទួលបានប្រាក់បំណាច់ខ្ពស់បំផុតក្នុងពិភពលោក ដែលជាយុទ្ធសាស្ត្រដ៏ជោគជ័យក្នុងការកាត់បន្ថយអំពើពុករលួយ។ ទោះបីជាយ៉ាងណា នៅក្នុងយុត្តាធិការអាស៊ាន ចៅក្រមជាទូទៅទទួលបានប្រាក់បៀរវត្សរ៍តិចតួច បើប្រៀបធៀបទៅនឹងប្រាក់បំណាច់របស់វិស័យឯកជន។ នៅប្រទេសហ្វីលីពីន ប្រាក់បៀវត្សរ៍របស់ចៅក្រម គឺមានកម្រិតត្រឹមតែ ៣០,០០០ប៉េសូ (ប្រហែល៦៩១ដុល្លារ) ដែលមានគម្លាតយ៉ាងខ្លាំងបើធៀបនឹងប្រាក់ខែនៅក្នុងវិស័យឯកជន។ ប្រាក់បៀវត្សរ៍តិច គឺជាមូលហេតុដ៏ចម្បងនៅប្រទេសហ្វីលីពីន ដែលធ្វើឲ្យមានចៅក្រមសរុប

តែ ២,៣០០នាក់ ប៉ុណ្ណោះ គឺជាតួលេខតិចជាងតម្រូវការ ដែលជាហេតុធ្វើឲ្យតុលាការតាមបណ្ដាខេត្តពុំមានដំណើរការ។

៨. ការទាមទារឲ្យមានឯករាជ្យភាពក្នុងវិស័យតុលាការ គឺមានចែងកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅប្រទេសថៃ ក្នុងគោលបំណងពង្រឹងស្ថាប័នឯករាជ្យ។ នៅឆ្នាំ២០០០ កិច្ចការរបស់តុលាការលែងស្ថិតក្រោមក្រសួងយុត្តិធម៌ទៀតទេ ដែលនេះជាការកាត់បន្ថយនូវការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងការងារតុលាការ។ វិធានការស្រដៀងគ្នានេះ ត្រូវបានគេយកទៅប្រើក្នុងប្រទេសហ្វីលីពីន ដូចជាការអនុម័តក្រមវិជ្ជាជីវៈចៅក្រមដោយតុលាការកំពូល។ ចំណែកឯ នៅប្រទេសឥណ្ឌូនេស៊ី គោលនយោបាយក្រោម "ដំបូលតែមួយ" បានទប់ស្កាត់រដ្ឋាភិបាលមិនឲ្យជ្រៀតជ្រែកក្នុងការតែងតាំង ការផ្ដល់តំណែង ការប្រគល់ភារកិច្ច ការដាក់ពិន័យ ឬការដកហូតដំណែងរបស់ចៅក្រម។ វិធានការនេះ គឺជាការធានានូវការបែងចែកអំណាច ផ្អែកលើយន្ដការការត្រួតពិនិត្យ និងតុល្យភាព ដូចដែលបានពន្យល់ខាងលើ គឺជាលក្ខខណ្ឌដំបូងសម្រាប់ភាពឯករាជ្យរបស់តុលាការ។

៩. ទោះបីជាវិធានការជាវិជ្ជមាននេះ ត្រូវបានបង្កើតឡើង ដើម្បីពង្រឹងសមត្ថភាព និងគុណភាពរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងស្រុក ក៏កិច្ចខិតខំប្រឹងប្រែងនេះអាចមិនទទួលបានជោគជ័យ ដោយការអនុវត្តន៍ផ្ទុយ។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីននីតិវិធីក្នុងការចាត់តាំងចៅក្រម គឺហាក់មានភាពតឹងរឹង ប៉ុន្តែជាក់ស្ដែងពុំត្រូវបានអនុវត្តទេ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា មតិភាគច្រើនពីចៅក្រម និងមេធាវីពុំបានពេញចិត្តចំពោះដំណើរការជ្រើសរើសនេះទេ។ ជាថ្មីម្ដងទៀត នៅប្រទេសហ្វីលីពីន ទោះបីជាមានស្ថាប័នអប់រំច្បាប់ និងបណ្ដុះបណ្ដាលចៅក្រមល្អៗ ប៉ុន្តែវាមិនបានឆ្លុះបញ្ចាំងថា ចៅក្រម និងអ្នកច្បាប់មានសមត្ថភាពខ្ពស់។

១០. ជាសេចក្ដីសន្និដ្ឋាន តាមរយៈរបាយការណ៍ប្រចាំប្រទេសនីមួយៗបានបង្ហាញថា ប្រទេសភាគច្រើននៅអាស៊ាន គឺមានកម្មវិធីកំណែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌ព្រមទាំងការពង្រឹងស្ថាប័នយុត្តិធម៌ ប៉ុន្តែការអនុវត្តន៍ជាក់ស្ដែងនៅមិនទាន់មានករាជ្យ និងនៅមិនទាន់បង្ហាញលទ្ធផលជាវិជ្ជមានទេ។ ការសិក្សាស្រាវជ្រាវរបស់យើងបានលើកជាសំណើថា កិច្ចខិតខំប្រឹងប្រែងនិងការវិវត្តន៍ឲ្យកាន់តែខ្លាំង គឺជាការចាំបាច់ ដើម្បីលើកកម្ពស់ស្តង់ដាររួម និងការអនុវត្តន៍ឲ្យបានត្រឹមត្រូវ សំដៅកសាងសមត្ថភាព និងឯករាជ្យភាពរបស់ស្ថាប័នតុលាការនៅក្នុងតំបន់ដែលមានសារៈសំខាន់ក្នុងការសម្រេចឲ្យបាននូវគោលដៅ និងគោលបំណងក្នុងការគាំទ្រការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងសន្តិសុខនយោបាយនៅឆ្នាំ២០១៥។

១១. ការសិក្សាជាមូលដ្ឋានរបស់យើង បានបង្ហាញពីចំណោទបញ្ហាក្នុងការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់ចៅក្រមក្នុងប្រទេសអាស៊ាន។ បញ្ហានេះកើតឡើងមកពីកត្តាជាច្រើន រួមមានគុណភាពនៃការអប់រំច្បាប់កម្រិតខ្ពស់ និងកម្រិតវិជ្ជាជីវៈ គុណភាពនៃការបណ្ដុះបណ្ដាលចៅក្រមបញ្ហាប្រាក់បៀវត្សរ៍ ឧបសគ្គក្នុងដំណើរការនីតិវិធីជ្រើសរើស និងកត្តាជាក់លាក់ជាច្រើនទៀត ដូចជា អំពើហិង្សាប្រឆាំងនឹងស្ថាប័នតុលាការ និងកង្វះបន្ទប់សវនាការដែលមានសន្តិសុខ និងសុវត្ថិភាពដល់ចៅក្រម។

១២. ការពង្រឹងស្ថាប័នតុលាការទាមទារនូវការលើកកម្ពស់ និងពង្រឹងសមត្ថភាពនិងភាពឯករាជ្យរបស់តុលាការ។ ប្រសិនបើផលប្រយោជន៍របស់ស្ថាប័ននីតិប្រតិបត្តិគ្របដណ្តប់ ឬជ្រៀតជ្រែកទៅក្នុងកិច្ចការតុលាការ ដូច្នេះ វិស័យតុលាការនៅតែទន់ខ្សោយ និងគ្មានប្រសិទ្ធភាព។ ការពង្រឹងសមត្ថភាព និងគុណតម្លៃរបស់តុលាការក្នុងស្រុកនឹងនាំមកនូវការព្យាករណ៍ច្បាប់ ដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់។ ការសិក្សាស្រាវជ្រាវលម្អិត អំពីការកសាងសមត្ថភាព និងអំពីសមត្ថកិច្ចរបស់តុលាការក្នុងតំបន់ គឺអាចបង្ហាញនូវមូលដ្ឋាន ដើម្បីផ្តល់ជាអនុសាសន៍ក្នុងការពង្រឹងស្ថាប័នតុលាការតាមរយៈការផ្តួចផ្តើមថ្នាក់តំបន់។

## គ. ការសន្និដ្ឋាន និងអនុសាសន៍

១. ជាថ្មីម្តងទៀត ធម្មនុញ្ញអាស៊ាន គឺជានិម្មិតរូបមួយដ៏សំខាន់ក្នុងការលើកកម្ពស់នីតិរដ្ឋ ដែលបង្ហាញពីទស្សនៈអភិបាលកិច្ចល្អ និងផ្សាភ្ជាប់ទៅនឹងការការពារសិទ្ធិមនុស្ស។

២. ក្នុងចំណោមកិច្ចការជាច្រើន គោលការណ៍ស្នូល ដែលយើងបានកំណត់ថា ជាមូលដ្ឋានក្នុងការវាយតម្លៃពីនីតិរដ្ឋ ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស គឺមិនត្រឹមតែការអនុម័តច្បាប់ ប៉ុន្តែទាំងការពង្រឹង និងការអនុវត្តន៍ច្បាប់ផងដែរ។ តម្រូវការចាំបាច់ក្នុងការបែងចែកអំណាចឲ្យបានច្បាស់រវាងអំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ គឺត្រូវឲ្យស្របនឹងបទប្បញ្ញត្តិ និងវិធាននានា។

៣. ការសិក្សាជាមូលដ្ឋានរបស់យើង បានបង្ហាញថា រដ្ឋជាសមាជិកអាស៊ានបានប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះគោលការណ៍ស្នូលទាំងនេះក្នុងការពង្រឹងនីតិរដ្ឋ ព្រមទាំងបញ្ចូលគោលការណ៍នេះនៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួន។

៤. ទោះបីជាយ៉ាងណាការពង្រឹងនីតិរដ្ឋ គឺពុំងាយស្រួលដូចជាការលើកឡើងទេ។ ក្នុងការអនុវត្តន៍ គឺទាមទារនូវបណ្តាវិធានការទាំងឡាយ ដែលបានរៀបរាប់នៅក្នុងរបាយការណ៍សង្ខេបនេះ។ បើទោះជា វិធានការមួយចំនួនសំខាន់ជាងវិធានការផ្សេងទៀត ប៉ុន្តែវិធានការទាំងនេះត្រូវតែរួមបញ្ចូលគ្នា ដើម្បីឲ្យសម្រេចបាននូវច្បាប់ និងយុត្តិធម៌ ដែលជាដំណើរឆ្ពោះទៅរកនីតិរដ្ឋប្រកបដោយចីរភាព។ ដូចដែលយើងបានឃើញថា ប្រទេសមួយចំនួននៅអាស៊ានបានអនុម័តស្ទើរគ្រប់វិធានការទាំងនេះ ចំណែកឯប្រទេសខ្លះទៀត នៅមិនទាន់បានអនុម័តនៅឡើយ។

៥. ការសិក្សាជាមូលដ្ឋានរបស់យើងសូមសន្និដ្ឋានដូចខាងក្រោម ដើម្បីជាជំនួយសម្រាប់ការស្រាវជ្រាវបន្ថែមទៀត។

៦. ទី១-ការសិក្សានេះបានបង្ហាញពីមូលដ្ឋាន និងពីចំណុចគោល ក្នុងការប្រមូលព័ត៌មានអំពីយន្តការនិងកម្មវិធី ដែលមាននៅក្នុងប្រទេសអាស៊ាននាពេលបច្ចុប្បន្ន ដើម្បីលើកកម្ពស់នីតិរដ្ឋ និងតុលាការ។

៧. ការសិក្សារបស់យើង បានបង្ហាញពីការឯកភាពយ៉ាងទូលាយនៅអាស៊ានពីការពង្រឹងនីតិរដ្ឋ។ ធម្មនុញ្ញអាស៊ានបានបង្ហាញនូវក្របខណ្ឌទស្សនៈនៃការយល់ដឹងពីសារៈសំខាន់នៃនីតិរដ្ឋ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលជាគោលការណ៍មានទំនាក់ទំនង និងជួយពង្រឹងការអនុវត្តន៍ទៅវិញទៅមក ហើយរដ្ឋជាសមាជិកត្រូវប្រឹងប្រែងការពារ និងលើកកម្ពស់។

៨. ទោះបីជាមានភាពខុសគ្នាពីវិសាលភាពនៃនីតិរដ្ឋ ដែលអនុម័តដោយរដ្ឋាភិបាលអាស៊ាន ក៏នៅតែប្រកាន់គោលការណ៍ការពារសិទ្ធិមនុស្ស។

៩. បញ្ហាលំបាកក្នុងការទទួលបានទិន្នន័យ ដែលពាក់ព័ន្ធនឹងសូចនាការ និងបទដ្ឋាននៃការអនុវត្តន៍នីតិរដ្ឋ ជាហេតុនាំឲ្យជួបឧបគ្គសសម្រាប់ការវាយតម្លៃអំពីនីតិរដ្ឋ។

១០. ជំហានបន្ទាប់ គួរធ្វើការវិភាគ ការស្រាវជ្រាវឲ្យកាន់តែស៊ីជម្រៅ ដែលអាចផ្តល់ជាមេរៀនដកពិសោធន៍ និងលើកជាអនុសាសន៍ទៅលើគោលនយោបាយដែលពាក់ព័ន្ធ។ ចំណែកឯការសិក្សាស្រាវជ្រាវបែបប្រៀបធៀប គឺអាចជាការវាយតម្លៃពីប្រសិទ្ធភាពនៃវិធានការក្នុងតំបន់ ដែលពិតជាមានអត្ថប្រយោជន៍ និងជាមេរៀនដកពិសោធន៍សម្រាប់ជួយរដ្ឋាភិបាលអាស៊ាន និងស្ថាប័នអន្តររដ្ឋាភិបាល ដើម្បីសម្រេចគោលដៅរួម និងការអនុវត្តន៍ល្អៗ។

១១. ម្យ៉ាងវិញទៀត មកដល់ពេលនេះ យើងពុំចាំបាច់ឲ្យមានការកំណត់ឲ្យច្បាស់ពីទស្សនៈស៊ីជម្រៅនៃនីតិរដ្ឋទេ ព្រោះចំណុចនេះបានពន្យល់យ៉ាងច្បាស់នៅក្នុងកថាខណ្ឌទី ២៧ ប៉ុន្តែយើងត្រូវពិណិនាឲ្យបានស៊ីជម្រៅពីបញ្ហាប្រឈម និងការអនុវត្តន៍នីតិរដ្ឋ។ ការបង្កើនការសិក្សាស្រាវជ្រាវលម្អិតលើការសិក្សាជាមូលដ្ឋាន គឺបង្ហាញពីយុទ្ធសាស្រ្តដ៏មានប្រសិទ្ធភាពសម្រាប់ការអនុវត្តន៍នីតិរដ្ឋ។

១២. ទី២-ដើម្បីជំរុញឲ្យមានការស្រាវជ្រាវបន្ថែម ការប្រមូលចងក្រងនូវទិន្នន័យ និងឯកសារផ្សេងៗ គឺជាគន្លឹះមួយដ៏សំខាន់។ នៅក្នុងករណីជាច្រើន អ្នកស្រាវជ្រាវប្រចាំប្រទេសនីមួយៗរបស់យើង ពុំអាចទទួលបានទិន្នន័យច្បាស់លាស់ ដោយសារការលាក់ការសម្ងាត់ ឬការពុំផ្សព្វផ្សាយជាសធារណៈ។ សមាជិកអាស៊ានអាចទទួលបានប្រយោជន៍ជាច្រើន ក្នុងការយកមកគិតពិចារណាពីបញ្ហាប្រឈម ដែលជួបប្រទះនៅថ្នាក់តំបន់ និងសិក្សាពីវិធីសាស្រ្ត ដែលប្រទេសនីមួយៗបានដោះស្រាយបញ្ហាទាំងនេះ។ ជំហានទី១ គឺត្រូវប្រមូលព័ត៌មាន ចងក្រងធ្វើជាឯកសារ និងការវិភាគឲ្យបានត្រឹមត្រូវ។ ព័ត៌មានទាំងនេះគួររក្សាទុកក្នុងប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធណាមួយ ដែលអាចងាយស្រួលដល់ការស្រាវជ្រាវពាក់ព័ន្ធនឹងគោលនយោបាយនានា។

១៣. ទី៣-ការសិក្សាស្រាវជ្រាវស៊ីជម្រៅបន្ថែមគួរធ្វើឡើង ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវពីវិធីសាស្រ្តកំណែទម្រង់នីតិរដ្ឋរបស់ប្រទេស និងស្ថាប័ននានានៅអាស៊ាន ទាញយកនូវមេរៀនទាក់ទងនឹងភាពជោគជ័យ និងបរាជ័យដើម្បីជាបទពិសោធន៍។ កំណត់ពីប្រភេទនៃបញ្ហា ដែលការសិក្សាស្រាវជ្រាវបន្ថែម គួរយកចិត្តទុកដាក់។

១៤. ទី៤-ដំណើរការកំណត់រកអ្នកស្រាវជ្រាវចំពោះការអនុវត្តន៍ការងារស្រាវជ្រាវជាមូលដ្ឋាន អំពីនីតិរដ្ឋនៅអាស៊ាន គឺមានការលំបាកដោយសារកង្វះអ្នកជំនាញលើវិស័យនេះ។ ដូច្នេះ សំខាន់ណាស់ គួរឲ្យមានការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវក្នុងប្រទេស។ ការស្រាវជ្រាវជាក់ស្តែងបន្ថែម ពុំអាចធ្វើបានទេ ប្រសិនបើគ្មានការដឹកនាំ ឬណែនាំបន្ថែម។

១៥. នៅក្នុងសេចក្តីសន្និដ្ឋាននេះ គឺជាអនុសាសន៍ សម្រាប់ការស្រាវជ្រាវបន្ថែម អំពីនីតិរដ្ឋ ការកំណែទម្រង់ និងការកសាងសមត្ថភាព៖

១.ធ្វើការស្រាវជ្រាវឲ្យបានស៊ីជម្រៅបន្ថែមដោយសហការជាមួយរដ្ឋជាសមាជិកអាស៊ាន និង AICHR ដើម្បីកំណត់នូវប្រធានបទជាក់លាក់ និងយន្តការគោលនយោបាយទូលំទូលាយ ឬលិខិតុបករណ៍នៅអាស៊ាន ក្នុងការពង្រឹងនីតិរដ្ឋ ដែលនៅមានភាពខ្វះចន្លោះ។

២.លើកកម្ពស់ការអប់រំ និងការយល់ដឹងអំពីសិទ្ធិមនុស្ស និងនីតិរដ្ឋ រួមទាំងការបង្កើតកម្មវិធីសិក្សាពីប្រព័ន្ធច្បាប់នៅអាស៊ាន និងទំនាក់ទំនងនៃគោលការណ៍ និងគោលបំណងដែលចែងក្នុងធម្មនុញ្ញអាស៊ាន រួមមាន ការលើកកម្ពស់នីតិរដ្ឋ និងអភិបាលកិច្ចល្អ និងការគោរព ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

៣.ការអភិវឌ្ឍន៍ និងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលពីបទដ្ឋាននីតិរដ្ឋ ការអនុវត្តន៍ល្អៗ និងក្របខណ្ឌច្បាប់សម្រាប់មន្ត្រីសង្គមស៊ីវិល និងអ្នកស្រាវជ្រាវមកពីបណ្តាក្រសួងនានានៅក្នុងប្រទេសអាស៊ានទាំង ១០។

៤.ការអភិវឌ្ឍន៍ និងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលតុលាការ សម្រាប់ចៅក្រមក្នុងតំបន់អាស៊ាន ដើម្បីពង្រឹងប្រព័ន្ធតុលាការ។

៥.ស្នើឡើងនូវសេចក្តីព្រាងដែលគាំទ្រ និងលើកកម្ពស់នីតិរដ្ឋ ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស និងការអនុវត្តន៍ល្អៗនៅក្នុងឆាកអន្តរជាតិ។

៦.ជំរុញឲ្យមានការបង្កើតបណ្តាញមេធាវីសិទ្ធិមនុស្សប្រចាំតំបន់ អ្នកស្រាវជ្រាវជាន់ខ្ពស់ចូលរួមក្នុងការសិក្សាអំពីគោលនយោបាយ ច្បាប់នីតិរដ្ឋ និងសិទ្ធិមនុស្សនៅអាស៊ាន ដើម្បីពង្រឹងសមត្ថភាព និងបង្កើនភាពឯកទេសក្នុងស្រុក។

៧.ប្រមូលចងក្រងបង្កើតមូលដ្ឋានទិន្នន័យអំពីនីតិរដ្ឋ ស្តីពីសិទ្ធិមនុស្ស ដែលអាចបម្រើជាមជ្ឈមណ្ឌលស្តុកទិន្នន័យពីគ្រប់ប្រទេសជាសមាជិកអាស៊ានទាំង១០ ហើយក៏ជាការតាមដាននូវសេចក្តីសម្រេចរបស់តុលាការសំខាន់ៗ និងភាពបម្រែបម្រួលនៃប្បញ្ញត្តិ ឬច្បាប់នានាដែលនាំឲ្យអាចជួយលើកកម្ពស់ ឬបង្អាក់ដំណើរការគោលការណ៍នីតិរដ្ឋ។

៨.សំណូមពរដល់ប្រទេសអាស៊ានទាំងអស់ ផ្សព្វផ្សាយឯកសារ និងទិន្នន័យព័ត៌មាន អំពីគោលការណ៍ស្នូលនៃនីតិរដ្ឋ ដែលបានលើកឡើងខាងលើ សម្រាប់បម្រើដល់ការស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល និងសាធារណជន ជាពិសេសផ្សព្វផ្សាយនូវស្ថិតិទាក់ទងនឹងដំណើរការកាត់ក្ដីរបស់តុលាការ ទាក់ទងនឹងរឿងក្ដីរំលោភសិទ្ធិមនុស្ស ដូចជា ចំនួនដាក់ពាក្យបណ្ដឹងការបិទការស៊ើបសួរ និងដំណោះស្រាយដល់ជនរងគ្រោះ។

៩.ការត្រួតពិនិត្យលើបទពិសោធន៍ និងយុត្តាធិការនៃគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិ និងស្ថាប័នឃ្លាំមើលសិទ្ធិមនុស្សនានា ដើម្បីពិចារណាពីមេរៀនដកពិសោធន៍ និងវិធីសាស្ត្រជួយពង្រឹងការអនុវត្តន៍។

១០.ស្នើឲ្យមានការសិក្សាស្រាវជ្រាវបន្ថែម ដែលធ្វើការសហការជាមួយ AICHR នៅក្នុងប្រធានបទអំពីការបង្កើតគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិ មជ្ឈមណ្ឌលស្រាវជ្រាវ ឬក៏ស្ថាប័នផ្សេងទៀត ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សក្នុងប្រទេសអាស៊ាន។

១១.ការស្រាវជ្រាវអំពីភាពខ្វះចន្លោះក្នុងការអនុវត្តន៍អនុសញ្ញាស្ដីពីសិទ្ធិកុមារ (CRC) និងអនុសញ្ញាស្ដីពី ការលុបបំបាត់ចោលរាល់ទម្រង់នៃរើសអើងប្រឆាំងស្ត្រី (CEDAW) នៅអាស៊ានក៏ដូចជារដ្ឋជាសមាជិកអាស៊ានបានផ្ដល់សច្ចាប័ន ឬយល់ព្រមលើលិខិតុបករណ៍ទាំងនេះ។

១២. ចំពោះលិខិតុបករណ៍អន្តរជាតិទាំងឡាយស្ដីពីសិទ្ធិមនុស្ស ប្រទេសមួយចំនួននៅអាស៊ាន ពុំទាន់បានផ្ដល់សច្ចាប័នទទួលយកនៅឡើយទេ ដូច្នេះ ការសិក្សាស្រាវជ្រាវបន្ថែមអំពីមូលដ្ឋានសិទ្ធិមនុស្ស ដែលមាននៅក្នុងប្រទេសនេះ មុននឹងទទួលយកលិខិតុបករណ៍អន្តរជាតិ ដូចជា ៖

ក- កិច្ចការ និងកាតព្វកិច្ច ដើម្បីការពារសិទ្ធិមនុស្ស
ខ- សិទ្ធិរបស់ជនជាតិភាគតិច និងជនជាតិដើម ក៏ដូចជាក្រុមសាសនាភាគតិច
គ- សិទ្ធិរបស់ជនភៀសខ្លួន អ្នកសុំជ្រកកោន និងការជម្លៀសចេញក្នុងស្រុក
ឃ-ការការពារទប់ស្កាត់នឹងការធ្វើទារុណកម្មការប្រមាថមើលងាយ និងអមនុស្សធម៌ព្រមទាំងការដកហូតជីវិតដោយពុំទទួលបានការជំនុំជម្រះក្ដី
ង- សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ រួមទាំងសិទ្ធិនៅដំណាក់កាលមុនការជំនុំជម្រះ (ការឃុំខ្លួន)
ច- សេរីភាពបញ្ចេញមតិ និងគំនិត រួមទាំងសារព័ត៌មាន
ឆ- សិទ្ធិទទួលបានអាហារ ទឹក អនាម័យ ទីជំរក ការថែរក្សាសុខភាព និងការអប់រំ
ជ- សិទ្ធិលើទ្រព្យសម្បត្តិ រួមទាំងសិទ្ធិកាន់កាប់ដីធ្លី និងរ៉ែ

១៣.កំណត់ត្រាពីការវិវត្តន៍នៃអង្គការសិទ្ធិមនុស្ស ដូចជា AICHR និង ACWC និងការផ្ដល់ការគាំទ្រចំពោះការស្រាវជ្រាវបន្ថែមលើប្រធានបទនេះ។

១៦. អាស៊ានកំពុងតែវិវត្តឆ្ពោះទៅកាន់ការធ្វើសមាហរណកម្មក្នុងតំបន់លើផ្នែកសន្តិសុខនយោបាយ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច យើងសង្ឃឹមថា ក្របខណ្ឌនៃគោលការណ៍ស្នូលអាចក្លាយទៅជា "នីតិរដ្ឋ" ដែលឯកសារនេះ បានលើកឡើងថា ពិតជាមានភាពចាំបាច់។ ការសិក្សានេះបានបង្ហាញពីមូលដ្ឋានគោលការណ៍ស្នូល និងការអនុវត្តន៍ទាក់ទងទៅនឹងនីតិរដ្ឋ ហើយបានបង្ហាញពីចំណុចគោលសម្រាប់វាយតម្លៃពីការអនុវត្តន៍នីតិរដ្ឋនៅក្នុងតំបន់។ បន្ទាប់ពីការស្ទាបស្ទង់មតិពីគោលការណ៍ និងការអនុវត្តន៍នៅក្នុងប្រទេសជាសមាជិកអាស៊ានទាំង១០ បានបង្ហាញថា ការរកវិធីសាស្ត្រឲ្យកាន់តែប្រសើរ ដើម្បីឈានទៅសម្រេចឲ្យបាននូវភាពជិតស្និទ្ធក្នុងតំបន់ គឺស្របតាមការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះនីតិរដ្ឋអភិបាលកិច្ចល្អ និងការបង្កើតសហគមន៍ច្បាប់មួយ ដោយចែករំលែកនូវគុណតម្លៃ និងបទដ្ឋាននានា។

## ឧបសម្ព័ន្ធទី ១ - សូចនាករ

<u>គោលការណ៍ស្នូលទី១ ៖ រដ្ឋាភិបាល មន្ត្រី និងភ្នាក់ងាររដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់</u>

១. តើអំណាចរបស់រដ្ឋាភិបាលត្រូវបានកំណត់ និងកម្រិតនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់គោលដទៃដែរឬទេ?

២. តើច្បាប់កំពូលអាចធ្វើវិសោធនកម្ម ឬព្យួរការអនុវត្តន៍ស្របតាមវិធាន និងនីតិវិធីដែលមានចែងក្នុងច្បាប់ដែរឬទេ?

៣. តើមន្ត្រី និងភ្នាក់ងាររដ្ឋាភិបាល រួមទាំងនគរបាល និងមន្ត្រីតុលាការ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះការប្រព្រឹត្តល្មើស រួមមានការរំលោភបំពានសិទ្ធិឯកជន ការអនុវត្តន៍ហួសបទបញ្ជា និងការរំលោភលើសិទ្ធិជាមូលដ្ឋាន?

<u>គោលការណ៍ស្នូលទី២ ៖ ច្បាប់ និងនីតិវិធីក្នុងការចាប់ខ្លួន ការឃុំខ្លួន និងដាក់ទណ្ឌកម្មដោយស្របច្បាប់ និងមិនលំអៀង</u>

១. តើក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ (រួមទាំងវិធានការរដ្ឋបាល ដែលផ្តល់ការការពារដល់ការឃុំឃាំង ឬវិធានទោសទណ្ឌ)មានការផ្សព្វផ្សាយ និងអាចស្វែងរកបានយ៉ាងទូលំទូលាយមានបច្ចុប្បន្នភាព និងអាចរកបានគ្រប់ភាសាផ្លូវការណ៍ដែរឬទេ?

២. តើច្បាប់ទាំងនេះងាយរកបានងាយស្រួលយល់ មិនមានប្រតិសកម្មអាចអនុវត្តអាចព្យាករណ៍មានភាពស្មើគ្នា និងសមស្របតាមច្បាប់ជារចរមាន?

៣. តើច្បាប់មានអំណាចរដ្ឋបាលវិធានការបង្ការការឃុំខ្លួនបណ្តោះអាសន្ន ដោយមិនមានការចោទប្រកាន់ ឬសវនាការក្នុងអំឡុងពេលឬក្រៅអំឡុងពេលដែលប្រទេសស្ថិតនៅក្នុងភាពអាសន្ន?

៤. តើច្បាប់ការពារជនជាប់ចោទពីការរំលោភបំពាន ឬការដាក់ទណ្ឌកម្មតាមទំនើងចិត្ត ឬហួសពីការកំណត់ដោយច្បាប់ ឬការដាក់ពិន័យរួមមានការប្រព្រឹត្តដោយអមនុស្សធម៌ការធ្វើទារុណកម្មការចាប់ខ្លួនតាម

អំពើចិត្ត ការឃុំខ្លួនដោយគ្មានការចោទប្រកាន់ ឬជំនុំជម្រះ និងការកាត់ទោសប្រហារជីវិតដោយខុសច្បាប់? តើសិទ្ធិ habeas corpus ត្រូវបានកំណត់ក្នុងកាលៈទេសៈណាដែរ?

៥. តើច្បាប់បានបញ្ញត្តិពីការសន្មតទុកជាមុនថាគ្មានទោសឬទេ?

៦. តើជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ ឬអាចប្រាស្រ័យទាក់ទងជាមួយមេធាវីដោយទៀងទាត់ ឬសិទ្ធិទទួលការតំណាងពីមេធាវីនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ ឬមេធាវីត្រូវបានតែងតាំងចំពោះជនជាប់ចោទដែលពុំមានលទ្ធភាពបង់ថ្លៃសេវាដែរឬទេ? តើជនជាប់ចោទត្រូវបានផ្តល់ព័ត៌មានពីសិទ្ធិទាំងនេះ ប្រសិនបើពួកគេគ្មានជំនួយផ្នែកច្បាប់?

៧. តើច្បាប់ធានាចំពោះជនជាប់ចោទនូវសិទ្ធិទទួលបានការផ្តល់ព័ត៌មាន អំពីការចោទប្រកាន់នៅក្នុងពេលសមស្រប ឬមានពេលវេលាគ្រប់គ្រាន់ក្នុងការពារខ្លួន និងទំនាក់ទំនងជាមួយមេធាវី?

៨. តើច្បាប់បានធានាដល់ជនជាប់ចោទនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេល ឬការជំនុំជម្រះចំពោះមុខជនជាប់ចោទ និងការការពារខ្លួនដោយខ្លួនឯង ឬដោយមេធាវី (ការសួរដេញដោលសាក្សី និងការពិនិត្យភស្តុតាង)?

៩. តើច្បាប់បានផ្តល់សិទ្ធិប្តឹងឧបាស្រ័យនៅតុលាការជាន់ខ្ពស់តាមនីតិវិធីច្បាប់ដែរឬទេ?

១០. តើច្បាប់បានហាមឃាត់ការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ "ជាភស្តុតាង" និងបានធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយដែរឬទេ?

១១. តើច្បាប់បានហាមឃាត់ចំពោះការជំនុំជម្រះ ឬផ្តន្ទាទោសជាលើកទីពីរចំពោះបទល្មើស ដែលតុលាការបានសម្រេចជាស្ថាពរមានទោស ឬគ្មានទោសដែរឬទេ?

១២. តើច្បាប់បានផ្តល់សិទ្ធិទាមទារសំណងឲ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាពនៅតុលាការចំពោះការរំលោភបំពានសិទ្ធិមូលដ្ឋានដែរឬទេ?

<u>**គោលការណ៍សួលទី៣ ៖ ដំណើរការច្បាប់ ដែលបានអនុម័ត និងបានអនុវត្តជាផ្លូវការណ៍ អាចរកបាន ឬត្រឹមត្រូវ ឬមានប្រសិទ្ធផលនិងយកទៅអនុវត្តដោយស្មើភាព**</u>

១. តើកិច្ចប្រជុំនីតិកម្មត្រូវបានជូនដំណឹងក្នុងពេលវេលាសមស្រប និងបើកចំហជាសាធារណៈដែរឬទេ?

២. តើសេចក្តីព្រាងច្បាប់ និងប្រតិចារិក ឬកំណត់ហេតុនៃសម័យប្រជុំនីតិកម្ម ត្រូវបានចែកជូនដល់សាធារណជនក្នុងពេលវេលាសមស្របដែរឬទេ?

៣. តើសិទ្ធិប្តឹងទៅតុលាការត្រូវបានកម្រិតជាក់លាក់ដោយរបៀបណាក្នុងការមិនឲ្យរើសអើង និងមិនរិតត្បិតហួសហេតុពេក?

៤. តើសវនាការ និងសេចក្តីសម្រេចរបស់តុលាការត្រូវធ្វើជាសាធារណៈ ហើយសេចក្តីសម្រេចត្រូវបានចេញដល់គូភាគីដែលមានផលប្រយោជន៍ភ្លាមៗដែរឬទេ?

៥. បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ តើមានសិទ្ធិទទួលបានការការពារពីច្បាប់ស្មើៗគ្នាដោយមិនមានការរើសអើងដែរឬទេ?

៦. តើបុគ្គលគ្រប់រូបអាចស្នើសុំជំនួយពីស្ថាប័នយុត្តិធម៌ដោយស្មើភាព មានប្រសិទ្ធិភាព និងមិនមានគំនាបយកកម្រៃដោយមិនត្រឹមត្រូវ ឬឧបសគ្គផ្នែករដ្ឋបាលផ្សេងៗដោយបំពានដែរឬទេ?

៧. តើច្បាប់ត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាព យុត្តិធម៌ និងស្មើភាពគ្នាដែរឬទេ? តើបុគ្គលដែលស្វែងរកយុត្តិធម៌ត្រូវបានផ្តល់ជំនួយសមស្របដែរឬទេ?

៨. តើច្បាប់បានផ្តល់សិទ្ធិទាមទារសំណងចំពោះការខូចខាតឲ្យបានគ្រប់គ្រាន់ មានប្រសិទ្ធិភាពនិងឆាប់រហ័សដល់ជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ ឬការរំលោភសិទ្ធិមនុស្សដែរឬទេ? តើជនរងគ្រោះទទួលបានព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការផ្តល់សំណងចំពោះការខូចខាតដែរឬទេ?

៩. តើច្បាប់បានបញ្ញត្តិ និងព្រះរាជអាជ្ញា ចៅក្រម ឬមន្ត្រីយុត្តិធម៌ បានចាត់វិធានការដើម្បីជួយការពារដល់សាក្សី និងជនរងគ្រោះ (និងអ្នកតំណាង) ពីការជ្រៀតជ្រែកជីវភាពឯកជនដោយខុសច្បាប់ ព្រមទាំងធានាសុវត្ថិភាពសាក្សីក៏ដូចជាក្រុមគ្រួសារពីការបំភិតបំភ័យ និងការសងសឹក នៅមុនពេលអំឡុងពេល និងក្រោយពេលដំណើរការជំនុំជម្រះ ឬដំណើរការរដ្ឋបាល ឬដំណើរការផ្សេងៗទៀត ដែលប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេដែរឬទេ?

<u>គោលការណ៍សួលទី៤ ៖ យុត្តិធម៌ត្រូវបានគ្រប់គ្រងដោយស្ថាប័នយុត្តិធម៌និងតុលាការឯករាជ្យ ដោយមិនលំអៀង និងមានសមត្ថភាព</u>

១. តើព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការត្រូវបានតែងតាំង ដំឡើងដំណែង ចាត់ចែងដាក់វិន័យ និងបណ្តេញចេញ ធ្វើឡើងដោយលក្ខណៈឯករាជ្យ និងគណនេយ្យភាពឬទេ?

២. តើព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការ ទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ធនធាន និងប្រាក់បៀវត្សរ៍ធនល្មមនឹងទំនួលខុសត្រូវរបស់ខ្លួនដែរឬទេ? តើថវិកាជាតិប៉ុន្មានភាគរយ ដែលបានបែងចែកសម្រាប់ស្ថាប័នតុលាការ និងស្ថាប័នយុត្តិធម៌ចម្បងៗដទៃទៀត?

៣. តើនីតិវិធីតុលាការត្រូវបានធ្វើឡើងដោយមិនលំអៀង និងមិនទទួលឥទ្ធិពលពីមន្ត្រីសាធារណៈ ឬក្រុមហ៊ុនឯកជនដែរឬទេ?

៤. តើតុលាការបានផ្តល់មេធាវីដល់ជនជាប់ចោទ សាក្សី និងជនរងគ្រោះ? តើមេធាវីប្រកបដោយសមត្ថភាពទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងមានចំនួនគ្រប់គ្រាន់ដែរឬទេ?

៥. តើនីតិវិធីច្បាប់ និងតុលាការធានានូវការផ្តល់សេវាគ្រប់គ្រាន់ធានាសុវត្ថិភាពដល់ជនជាប់ចោទ ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីយុត្តិធម៌ មុនពេលអំឡុងពេល និងក្រោយពេលដំណើរការជំនុំជម្រះក្តី ដំណើរការរដ្ឋបាល និងដំណើរការដទៃទៀតដែរឬទេ? តើមានការធានាដល់សាធារណជន និងភាគីដែលពាក់ព័ន្ធក្នុងអំឡុងពេលដំណើរការនីតិវិធីដែរឬទេ?

## ឧបសម្ព័ន្ធទី ២ - តារាងនីតិរដ្ឋអាស៊ាន

| | ប្រ៊ុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ភូមា | ហ្វីលីពីន | សិង្ហបុរី | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|---|
| ភាគីក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ | | | | | | | | | | |
| អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មបទឧក្រិដ្ឋប្រល័យពូជសាសន៍ | x | x | | x | x | x | x | x | | x |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងពូជសាសន៍ | | x | x | x | | | x | | x | x |
| អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងស៊ីវិល (ICCPR) | | x | x | x | | | x | | x | x |
| ពិធីសារជម្រើសចំពោះអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងស៊ីវិល (ICCPR) | | x | | | | | x | | | |
| ពិធីសារជម្រើសទី២ ចំពោះអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងស៊ីវិល(ICCPR) ក្នុងគោលបំណងលុបចោលនូវទោសប្រហារជីវិត | | | | | | | x | | | |
| អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) | | x | x | x | | | x | | x | x |
| ពិធីសារជម្រើសចំពោះអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) | | | | | | | | | | |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងស្ត្រី (CEDAW) | x | x | x | x | x | x | x | x | x | x |
| ពិធីសារជម្រើសចំពោះអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើ | | x | x | | | | x | | x | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សអើងប្រឆាំងស្ត្រី (CEDAW) | | | | | | | | | | |
| អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ការប្រព្រឹត្តមើលងាយ អមនុស្សធម៌ និងអំពើយង់ឃ្នងដទៃទៀត ឬដាក់ទណ្ឌកម្ម | | X | X | | | | X | | X | |
| ពិធីសារជម្រើសចំពោះអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ការប្រព្រឹត្តមើលងាយ អមនុស្សធម៌ និងអំពើយង់ឃ្នងដទៃទៀត ឬដាក់ទណ្ឌកម្ម | | X | | | | | | | | |
| អនុសញ្ញាស្តីពីសិទ្ធិកុមារ | X | X | X | X | X | X | X | X | X | X |
| ពិធីសារជម្រើសស្តីពីចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការពាក់ព័ន្ធកុមារទៅក្នុងសង្គ្រាមប្រដាប់អាវុធ | | X | X | | | | X | | X | X |
| ពិធីសារជម្រើសចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការជួញដូរកុមារ ពេស្យាចារកុមារ និងអាសគ្រាមលើកុមារ | | X | X | | | | X | | X | X |
| លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ | | X | | | X | | X | | | |
| អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់គេ | | X | | | | | X | | | |
| អនុសញ្ញាស្តីពីសិទ្ធិបុគ្គល និងជនពិការ | | X | | X | X | | X | | X | |
| ពិធីសារជម្រើសចំពោះអនុសញ្ញាស្តីពីសិទ្ធិបុគ្គល និងជនពិការ | | X | | | | | | | | |
| អនុសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលទាំងអស់ពីការបង្ខំឲ្យបាត់ខ្លួន | | | X | | | | | | | |
| អនុសញ្ញាទីក្រុងហ្សឺណែវ(I)សម្រាប់ការលើកកម្ពស់ស្ថានការណ៍នៃការរងរបួស និងមានជំងឺក្នុងជួរកងទ័ពនៅសមរភូមិ ឆ្នាំ១៩៤៩ | X | X | X | X | X | X | X | X | X | X |
| អនុសញ្ញាទីក្រុងហ្សឺណែវ(II)សម្រាប់ការលើកកម្ពស់ស្ថានការណ៍នៃការរងរបួស និងមានជំងឺនិងសមាជិកនាវាក្នុងជួរកងទ័ពនៅសមុទ្រ ឆ្នាំ១៩៤៩ | X | X | X | X | X | X | X | X | X | X |
| អនុសញ្ញាទីក្រុងហ្សឺណែវ(III)ទាក់ទងនឹងការព្យាបាលអ្នកទោសក្នុងសង្គ្រាម ឆ្នាំ១៩៤៩ | X | X | X | X | X | X | X | X | X | X |
| អនុសញ្ញាទីក្រុងហ្សឺណែវ(IV) ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ឆ្នាំ១៩៤៩ | X | X | X | X | X | X | X | X | X | X |
| ១៩៧៧ ពិធីសារបន្ថែមចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ សីហា ១៩៤៩ ដែលទាក់ទងទៅនឹងការការពារជនរងគ្រោះក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី១) | X | X | | X | | | | | | X |
| ១៩៧៧ ពិធីសារបន្ថែមចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ សីហា ១៩៤៩ ដែលទាក់ទងទៅនឹងការការពារជនរងគ្រោះក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី២) | X | X | | X | | | X | | | |
| ២០០៥ ពិធីសារបន្ថែមចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ សីហា ១៩៤៩ ដែលទាក់ទងទៅនឹងការអនុម័តស្លាកសញ្ញាផ្សេងបន្ថែម (ពិធីសារទី៣) | | | | | | | X | X | | |
| អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដោយគ្រោងទុក | | X | X | X | X | X | X | X | X | X |
| ពិធីសារទប់ស្កាត់ ការគាបសង្កត់ ការដាក់ទណ្ឌកម្មចំពោះការជួញដូរបុគ្គល ជាពិសេសស្ត្រី និងកុមារ | | X | X | X | X | X | X | | X | |
| ពិធីសារស្តីពីការប្រឆាំងនឹងការរត់ពន្ធពលករតាមជើងគោក ទឹក និងអាកាស | | X | X | X | | X | X | | X | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៩៥១ អនុសញ្ញាពាក់ព័ន្ធនឹងស្ថានភាពនៃជនភាសខ្លួន និងពិធីសារ១៩៦៧ | | X | | | | | X | | | |
| អនុសញ្ញា១៩៥៤ទាក់ទងនឹងស្ថានភាពបុគ្គលមិនមានសញ្ជាតិច្បាស់លាស់ | | | | | | | X | | | |
| អនុសញ្ញា១៩៦១អំពីការកាត់បន្ថយភាពគ្មានសញ្ជាតិច្បាស់លាស់ | | | | | | | | | | |
| អនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ | X | | X | | | | X | | | X |
| គោលការណ៍ស្នូលទី ១- រដ្ឋាភិបាល មន្ត្រី និងភ្នាក់ងាររដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ | | | | | | | | | | |
| តើរដ្ឋធម្មនុញ្ញធានានូវការបែងចែងអំណាចឬទេ? | គ្មាន | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | មាន | មាន |
| តើសិទ្ធិមូលដ្ឋានត្រូវបានការពារ ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់មូលដ្ឋានដទៃទៀតឬទេ? | គ្មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន |
| តើមានច្បាប់សន្តិសុខផ្ទៃក្នុង ឬអាសន្ន ដែលកម្រិតសិទ្ធិមូលដ្ឋាន និងអនុញ្ញាតឲ្យមានការឃុំខ្លួនដោយគ្មានការកាត់ទោសឬទេ? | មាន | គ្មាន | មាន | គ្មាន | មាន | មាន | មាន | មាន | មាន | មាន |
| គោលការណ៍ស្នូលទី ២- ច្បាប់ និងនីតិវិធីចាប់ខ្លួន ឃុំខ្លួន ដាក់ទណ្ឌកម្ម អាចរកបានជាសាធារណៈ ដោយស្របច្បាប់ និងមិនលំអៀង | | | | | | | | | | |
| តើច្បាប់ហាមឃាត់ការធ្វើទណ្ឌកម្ម និងការប្រព្រឹត្តអនុស្សធម៌ និងសាហាវព្រៃផ្សៃក្នុងកន្លែងឃុំឃាំងឬទេ? | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | មាន | មាន | មាន |
| តើច្បាប់មានចែងពីការអាចទទួលបានការប្រឹក្សាច្បាប់ឬទេ? | មាន | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | មាន | មាន |
| តើច្បាប់ធានាសម្រាប់ជនជាប់ចោទនូវសិទ្ធិទទួលបានព័ត៌មានពីការចោទប្រកាន់ច្បាស់លាស់ប្រឆាំងនឹងគេទាន់ពេលវេលាឬទេ? | មាន | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | មាន | មាន |
| តើច្បាប់ទាំងនេះធានាសម្រាប់ជនជាប់ចោទឲ្យមានសិទ្ធិទទួលបានការកាត់ទោស ដោយគ្មានការពន្យារពេលឬទេ? | មាន | មាន | មាន | មាន | គ្មាន | គ្មាន | មាន | គ្មាន | មាន | មាន |
| តើសាធារណជនអាចរកបានដោយងាយនូវច្បាប់ព្រហ្មទណ្ឌឬទេ? | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន |
| តើច្បាប់នេះពិតជាផ្តល់នូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចោទប្រកាន់ ឬការកាត់ទោសទៅតុលាការជាន់ខ្ពស់បន្ទាប់យោងតាមច្បាប់ឬទេ? | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន |
| គោលការណ៍ស្នូលទី ៣- ដំណើរការអនុម័តច្បាប់ និងអនុវត្តអាចចូលរួមបាន ត្រឹមត្រូវ ប្រសិទ្ធផល និងអនុវត្តស្មើៗគ្នា | | | | | | | | | | |
| តើមានការផ្តល់សេចក្តីជូនដំណឹងទាន់ពេលវេលា និងបើកចំហជាសាធារណៈពីដំណើរការធ្វើច្បាប់ឬទេ? | គ្មាន | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | មាន | មាន |
| តើសេចក្តីព្រាងច្បាប់ផ្លូវការ និងសេចក្តីពណ៌នា ឬកំណត់ហេតុនៃដំណើរការធ្វើច្បាប់បើកទូលាយ សម្រាប់សាធារណជនទាន់ពេលវេលាឬទេ? | គ្មាន | មាន | គ្មាន | គ្មាន | មាន | គ្មាន | មាន | មាន | មាន | គ្មាន |
| តើសវនាការតុលាការ និងសេចក្តីសម្រេចជាសាធារណៈ ត្រៀមជាស្រេចសម្រាប់ភាគី ដែលប៉ះពាល់ឬទេ? | មាន | មាន | គ្មាន | មាន | មាន | មាន | មាន | មាន | មាន | មាន |
| តើបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយគ្មានការរើសអើងចំពោះការទទួលការការពារស្មើគ្នានៃច្បាប់ឬទេ? | គ្មាន | មាន | គ្មាន | មាន | មាន | មាន | មាន | មាន | មាន | មាន |
| គោលការណ៍ស្នូលទី ៤- យុត្តិធម៌គ្រប់គ្រងដោយស្ថាប័នយុត្តិធម៌ និងតុលាការ ដែលឯករាជ្យ មិនលំអៀង និងមានសមត្ថភាព | | | | | | | | | | |
| តើថវិកាជាតិប៉ុន្មានភាគរយ ដែលបែងចែកសម្រាប់ដំណើរការតុលាការ? | មិនដឹង | 0.៨២% | ៩.១៥% | មិនដឹង | មិនដឹង | មិនដឹង | 0.៨៧% | 0.៦៦% | ៤.៦៨៨% | មិនដឹង |
| តើការងារតុលាការមានអាណត្តិឬទេ? | មាន | មាន | មាន | គ្មាន | មាន | គ្មាន | មាន | មាន | មាន | គ្មាន |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| តើមាននីតិវិធីច្បាប់ ដែលធានាសិទ្ធិចូលរួម សុវត្ថិភាព និងសន្តិសុខសម្រាប់គ្រប់ភាគី មុនពេល ក្នុងកំលុងពេល និងក្រោយពេលកាត់ក្តីឬទេ? | មាន | មាន | មាន | មាន | មាន | គ្មាន | មាន | មាន | គ្មាន | មាន |
| មានការបណ្តុះបណ្តាលច្បាប់ជាបន្តបន្ទាប់ឬទេ? | មាន | មាន | មាន | | មាន | មាន | មាន | | មាន | មាន |
| មានករណីនៅចំពោះមុខគណៈកម្មការសិទ្ធិមនុស្ស ឬ គណៈកម្មការឯករាជ្យដទៃទៀតឬទេ? | មិនអាចរកបាន | មិនអាចរកបាន | ៥៣៧ | មិនអាចរកបាន | ៥២៦ | មិនអាចរកបាន | ៥៩៩ | មិនអាចរកបាន | ៦៩៥ | មិនអាចរកបាន |
| មានបណ្តឹងប្រឆាំងនឹងនគរបាល តុលាការ ឬស្ថាប័នរដ្ឋឬទេ? | មិនដឹង | មិនអាចរកបាន | ៦៣៥៦ | គ្មាន | មិនអាចរកបាន | មិនដឹង | មិនដឹង | មិនអាចរកបាន | ៥២០៦ | មិនអាចរកបាន |
| បើមាន មានប៉ុន្មាន ដែលត្រូវបានដោះស្រាយ? | មិនអាចរកបាន | មិនអាចរកបាន | ២៣៥៣ | មិនអាចរកបាន | មិនមានតួរលេខ | មិនដឹង | មិនដឹង | មិនអាចរកបាន | មិនដឹង | មិនអាចរកបាន |

[i] I am grateful for the excellent assistance of the HRRC Rule of Law Research Coordinators Mr. Joel Ng, Ms. Sarah Shi and Ms. Lan Shiow Tsai.

[ii] Erik G. Jensen, "Justice and the Rule of Law", in Charles T. Call & Vanessa Wyeth, *Building States to Build Peace* (2008), at 123.

[iii] *Ibid.*

[iv] See JOSEPH RAZ, *The Rule of Law and its Virtue*, in THE AUTHORITY OF LAW: Essays on Law & Morality, 210, at 214-216 (1983).

[v] *Ibid*, at 212.

[vi] Gordon Barron, *The World Bank & Rule of Law Reforms* 32 (Dev. Studies Inst. Working Paper No. 05-70, 2005), *available at*www.lse.ac.uk/collections/DESTIN/pdf/WP70.pdf.

[vii] *Ibid*, at 32.

[viii] Richard A. Posner, *A Constitutional Law from a Pragmatic Perspective*, 55 U. Toronto LJ, 299, at 299 (2005).

[ix] "Law Society Failed to Defend Legal System: AG", *Straits Times*, 18 November 1995, 1.

[x] Rais Yatim *Freedom Under Executive Power in Malaysia: A Study of Executive Supremacy*, Kuala Lumpur, Endowment Publications, 1995, at p. 27.

[xi] Tim Lindsey, "Indonesia: Devaluing Asian Values, Rewriting Rule of Law," in Randall Peerenboom ed., *Asian Discourses of Rule of Law: Theories and Implementation of Rule of Law in Twelve Asian countries, France and the U.S.,* (London: Routledge, 2004): 286-323, at 295.

[xii] HANS THOOLEN, INDONESIA AND THE RULE OF LAW: TWENTY YEARS OF "NEW ORDER" GOVERNMENT (1987).

[xiii] Thom Ringer, Development, Reform, andtheRuleof Law: Some Prescriptions for a Common Understanding ofthe 'Rule of Law' and its Place in Development Theory and Practice, Yale Human Rights andDevelopmentLaw Journal, Vol. 10, No. 1, 2007, p.196.

[xiv] Ronald Bruce St John, 2006, *Revolution, Reform and Regionalism in Southeast Asia: Cambodia, Laos and Vietnam*, Oxford: Routledge, p. 100.

[xv] See MICHAEL NEUMANN, THE RULE OF LAW: POLITICIZING ETHICS 3 (2002). See Also CASS R. SUNSTEIN, DESIGNING DEMOCRACY: WHAT CONSTITUTIONS DO 7 (2001).

[xvi] Abhisit Vejjajiva, *The Policy Statement of the Council of Ministers to the National Assembly*, December 29, 2008.

[xvii] See William C. Whitford, *The Rule of Law*, 2000, WIS. L. Rev, 723 (2000).

[xviii] Thomas. Carothers, *The Rule of Law Revival,* FOREIGN AFFAIRS, Mar-April 1988, at 95["One cannot get through a foreign policy debate these days without someone proposing the rule of law as a solution to the world's troubles"]. See also Paul Craig, *Formal and Substantive Conceptions of the Rule of Law: An analytical*

*Framework, 1997* PUB.L.467, at 487 (1997) ["the adoption of a fully substantive conception of the rule of law has the consequence of robbing the concept of any function which is independent of the theory of justice which imbues an account of law".]

[xix]Brian Z. Tamanaha, "On The Rule of Law: History, Politics, Theory" Publisher: Cambridge University Press, 2004 at 113.

[xx]Public participation in legal reform and legal awareness projects has often been poorly conceived and ineffective. See Erik G. Jensen, "*Meaningful Participation or Deliberative Deception: Realities and Dilemmas in Legitimating Legal and Judicial Reform Projects through Consultative Processes"*, paper presented at World Bank Lawyers Forum, November 4-5, 1999, Washington DC.

[xxi]Kim Ninh & Roger Henke, *"Commune Councils in Cambodia: A National Survey of Their Functions and Performance, with a Special Focus on Conflict Resolution"*, (Asia Foundation, May 2005), available at http://asiafoundation.org/pdf/CB-CCSurvey.pdf

[xxii]Vitit Muntarbhorn, "Rule of Law and Aspects of Human Rights in Thailand", Randall Peerenboom (ed*.), Asian Discourses of Rule of Law, Theories and Implementation of Rule of Law in Twelve Asian Countries, France and the US* London, New York, Routledge Curzon, 2004, p. 1.

[xxiii]Jeremy Waldron, *Rights and Majorities: Rousseau Revisited*, in Liberal Rights, 417-18.

[xxiv]*Ibid* at 114.

[xxv]Randall Peerenboom, "Varieties of Rule of Law: An Introduction and Provisional Conclusion", in Randall Peerenboom (ed*.), Asian Discourses of Rule of Law, Theories and Implementation of Rule of Law in Twelve Asian Countries, France and the US* London, New York, Routledge Curzon, 2004, at 45.

[xxvi]See generally Randall Peerenboom (ed*.), Asian Discourses of Rule of Law, Theories and Implementation of Rule of Law in Twelve Asian Countries, France and the US* London, New York, Routledge Curzon, 2004.

[xxvii]*Ibid*.

[xxviii]*Ibid,* at 45.

[xxix]*Ibid,* at 47.

[xxx]Secretary-General to the Security Council.*The Rule of Law and Transitional Justice in Conflict and Post-Conflict Societies.*(United Nations Security Council, 2004, S/2004/616*), 4.

[xxxi]UN Secretary-General (UNSG), *Guidance Note of the Secretary-General: United Nations Approach to Rule of Law Assistance*, 14 April 2008, at 1.

[xxxii]*Ibid*, at 1.

[xxxiii]New York, 11 April 2011 - The Secretary-General's remarks to General Assembly on "The Rule Of Law And Global Challenges" [As delivered] Office of the Spokesperson of the Secretary-General http://www.un.org/apps/sg/sgstats.asp?nid=5198.

[xxxiv]Erik G. Jensen, "Justice and the Rule of Law", in Charles T. Call & Vanessa Wyeth, *Building States to Build Peace* (2008) ["The rule of law is bandied about by politicians and development professionals alike as if we have a common conception of the term. We don't. It is hotly contested. At a minimum, just being aware of the basic elements of the rich definitional debate should improve the practice of strengthening it"].

[xxxv]General Assembly, 05-48760 Resolution adopted by the General Assembly [without reference to a Main Committee (A/60/L.1)] 60/1.2005 World Summit Outcome 24 October 2005, Sixtieth session, Agenda items 46 and 120.

[xxxvi]Brian Tamanaha, Brian On the Rule of Law: History, Politics, CUP / 2005 at 111.

[xxxvii]Thomas. Carothers, *The Rule of Law Revival,* FOREIGN AFFAIRS, Mar-April 1988, at 95.

[xxxviii]Rodolfo C. Severino, "ASEAN Way and the Rule of Law", address at the International Law Conference on ASEAN Legal Systems and Regional Integration sponsored by the Asia-Europe Institute and the Faculty of Law, University of Malaya, Kuala Lumpur, 3 September 2001.

[xxxix]*Id*.

[xl]2007 Charter of the Association of Southeast Asian Nations signed on 20 November 2007 in Singapore by the Heads of State/Government.

[xli]*Ibid.*

[xlii]Rodolfo C. Severino, "The ASEAN Charter: One Year On", Opinion Asia, 3 January 2010, available at http://opinionasia.com/ASEANCharterOneyearon

[xliii]2009 Cha-am Hua Hin Declaration on the Roadmap for an ASEAN Community (2009-2015) signed on 1 March 2009 in Cha-am by the Heads of State/Government.

[xliv]*Ibid*, para 12.

[xlv]*Ibid*, para 15.

[xlvi]2009 Terms of Reference of ASEAN Intergovernmental Commission on Human Rights adopted on 20 July 2009 in Phuket, Thailand by the Foreign Ministers, Article 2.1(d).

[xlvii]Tan Sri Ahmad Fuzi bin Abdul Razak, ***Facing Unfair Criticisms*****, in** The Making of the ASEAN Charter,**edited by Tommy Koh, Rosario Gonzalez-Manalo & Walter Woon, at 21-22.**
[xlviii]Inspired by the UN definition, similar principles have been affirmed and used in other indices such as the World Justice Project (WJP), which has developed a Rule of Law Index to measure the extent to which countries adhere to the rule of law in practice. The WJP Rule of Law Index is composed of 10 factors and 49 sub-factors, including the four central principles we have selected.
[xlix]Matthieu Salomon and Vu Doan Ket, 2010, "Achievements and challenges in developing a law-based state in contemporary Vietnam: How to shoe a turtle?" in John Gillespie and Albert H.Y. Chen (eds.) *Legal Reforms in China and Vietnam: A comparison of Asian Communist regimes*, London & New York: Routledge, p. 141.
[l]Penelope Nicholson, "Vietnamese Courts: Contemporary Interactions between Party-State and Law," in Stephanie Balme and Mark Sidel, 2007, *Vietnam's New Order: International Perspectives on the State and Reform in Vietnam*, New York: Palgrave Macmillan, p. 179.
[li]Nguyen Hung Quang, "Lawyers and Prosecutors under Legal Reform in Vietnam: The Problem of Equality" in Stephanie Balme and Mark Sidel, 2007, *Vietnam's New Order: International Perspectives on the State and Reform in Vietnam*, New York: Palgrave Macmillan, p. 168.
[lii]Revised Penal Code, Article 235.
[liii]Revised Penal Code, Article 269 and Article 124.
[liv]According to human rights group Karapatan, during Arroyo's 9-year administration, there were 1,206 victims of extrajudicial execution; 379 victims of frustrated killing; 206 victims of enforced disappearance; 1,099 victims of torture; 2,059 victims of illegal arrest; and 53,893 victims of illegal search and seizure, Karapatan, 2010 Year-End Report on the Human Rights Situation in the Philippines, 1 December 2010, 25.
[lv]Jam L. Sisante and Sophia Dedace, *GMANews.TV*, "Govt to form new task force on extrajudicial killings", 10 December 2010, <http://www.gmanews.tv/story/208037/govt-to-form-new-task-force-on-extrajudicial-killings>, (20 December 2010).
[lvi]Linda Luz Guerrero, Mahar Mangahas and Marlon Manuel, *Social Weather Stations*, *"*New SWS Study of the Judiciary and the Legal Profession Sees Some Improvements, But Also Recurring Problems",25 January 2005,<http://www.sws.org.ph/pr050125.htm>, (04 December 2010).
[lvii]Civil Code of the Philippines, Article 2; *and*Executive Order 200 (1987).
[lviii]See Ross Cranston, *How Law Works – The Machinery and Impact of Civil Justice* (Oxford University Press, 2006), p. 36.
[lix]See AP, Armando Siahaan & Camelia Pasandaran, "Gayus Tambunan Case Symbolic of Indonesia's Woes," *Jakarta Globe*, 18 November 2010, <http://www.thejakartaglobe.com/home/gayus-tambunan-case-symbolic-of-indonesias-woes/407147>, accessed 31 January 2011.
[lx]"CJ Chan Sek Keong receives top jurist award", *The Straits Times*: B20, 26 November 2009.
[lxi]Report of the Special Rapporteur on the independence of judges and lawyers, Dato Param Cumaraswamy, UN Doc. E/CN.4/1996/37 (Commission on Human Rights, 52nd session), para 218 ["The very high number of cases won by the Government or members of the ruling party in either contempt of court proceedings of defamation suits brought against critics of the Government, be they individuals or the media, particularly from a liberal perspective"].